# ឱឃៈ ៤ ប្រការ



# អារម្ភកថា

បុព្វហេតុ ដែលនាំឱ្យខ្ញុំព្រះករុណាអាត្មាភាព សរសេរចងក្រងនូវសៀវភៅឈ្មោះ **ឱឃៈ** អន្លង់ ៤ ប្រការនេះឡើង ក្នុងគោលបំណង សម្រាប់ជាធម្មទាន ក្នុងកម្មវិធីបុណ្យឆ្លង ព្រហ្មចរិយៈសាលា មណ្ឌលវិបស្សនាធុរៈព្រៃដែន ក្អមសំណរនាថ្ងៃសៅរ៍ ទី៧ ខែមេសា ឆ្នាំ ព.ស. ២៥៥៥ / គ.ស. ២០១២

ដោយយល់ឃើញថា ពុទ្ធបរិស័ទភាគច្រើន បំពេញបុណ្យកុសល តែងតែប្រាថ្នាឱ្យបានឆ្លងផុតចាកសេចក្ដីទុក្ខ ហើយសត្វទាំងអស់ដែលមិនបានសេចក្ដីសុខ ក៏ព្រោះតែលិចលង់ក្នុងអន្លង់គឺ កាម ភព ទិដ្ឋិ អវិជ្ជា នេះឯង។

ហើយដោយយល់ឃើញថា ពុទ្ធបរិស័ទទាំងឡាយ មិនយល់អំពីការឆ្លងសេចក្តីទុក្ខបានដោយសារអ្វី ចេះតែយល់តៗគ្នាថា ការឆ្លងគឺព្រះសង្ឃជាអ្នកឆ្លង ឬអាចារ្យជាអ្នកចម្លងឱ្យខ្លួនទៅវិញ ដោយមិនបានដឹងថា ខ្លួនឯងជាអ្នកឆ្លងនូវសេចក្តីទុក្ខបានដោយសារខ្លួននោះទេ។

ដូច្នេះ ក្នុងអត្ថន័យសៀវភៅនេះ ខ្ញុំព្រះករុណាអាត្មាភាព សង្ឃឹមថា នឹងបានជាគុណប្រយោជន៍ដល់សតិបញ្ញា ព្រះករុណាគ្រប់អង្គព្រមទាំងពុទ្ធបរិស័ទទាំងឡាយ សិក្សាប្រតិបត្តិដើម្បីឆ្លងរួចចាកទុក្ខបាន។

*កល្យាណមិត្តមានឧបការៈក្នុងសៀវភៅនេះ*

១.សូមថ្លែងអំណរគុណចំពោះ **ព្រះធម្មាចារ្យ ខឹម សុខឿន អប្បមត្តោ** ដែលបានជួយពិនិត្យ និងជួយប្រមូលឯកសារ។

២.សូមថ្លែងអំណរគុណចំពោះ **ព្រះមហា ហ៊ិល សុខគា កល្យាណធម្មោ** ជាសមណនិស្សិតនៃសាកលវិទ្យាល័យព្រះសីហនុរាជ ដែលបានជួយពិនិត្យ និងយកអត្ថបទវាយបញ្ចូលកុំព្យូទ័រ។

៣.សូមថ្លែងអំណរគុណចំពោះ **ព្រះញាណវង្ស ខឹម សន ព្រះមេគណរាជធានីភ្នំពេញ** ដែលបានជួយពិនិត្យ និងសម្រួលសៀវភៅនេះអោយកាន់តែប្រសើរឡើង។

# ឧទ្ទិសកថា

ដោយអំណាចធម្មទាននេះ សូមថ្វាយប្រគេនសម្តេច ជួន ណាត (ជ.ណ) និងសមណសង្ឃគ្រប់ឋានានុក្រម។

សូមប្រគេនចំពោះ **ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ** សូមឱ្យព្រះអង្គបានសម្រេចជាព្រះពុទ្ធកុំបីខាន។

ឧទ្ទិសទៅដល់ញាតិការគ្រប់សន្តានទាំងអស់ដែលបានចែកឋានទៅកាន់បរលោកនាយហើយនោះ សូមឱ្យរួចចាកទុក្ខទោសកុំបីខាន។

# សេចក្តីថ្លែងអំណរគុណ

សូមជូនបុណ្យដល់ញោមប្រុស **មា សាន់** និងញោមស្រី **ចន្ទ ស្រេង** កំពុងតែរស់នៅ និងបងប្អូនប្រុសស្រីញាតិមិត្តទាំងអស់ សូមឱ្យបានសេចក្តីសុខរួចចាកទុក្ខកុំបីខានឡើយ។

សូមឱ្យសប្បុរសទាំងអស់ ដែលបានឧបត្ថម្ភៈក្នុងការបោះពុម្ពសៀវភៅនេះ សូមឱ្យមានប្រាជ្ញាជាសម្មាទិដ្ឋិគ្រប់ៗគ្នា បានសម្រេចនូវលោកុត្តរធម៌គឺ មគ្គ ៤ ផល ៤ និព្វាន ១។

សូមឱ្យសព្វសត្វទាំងអស់បានឆ្លងរួចចាកទុក្ខដល់បរមសុខគឺ ព្រះនិព្វាន។

ច

ថ្ងៃ អាទិត្យ ៨ កើត ខែ បុស្ស ឆ្នាំថោះ ត្រីស័ក

ព.ស. ២៥៥៥

ត្រូវនឹងថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២

**ព្រះធម្មាចារ្យ ទុំ វចនា រក្ខិតសីលោ**

# មាតិកា

អារម្ភកថា ------------------------------ ក

ឧទ្ទិសកថា -------------------------------- គ

សេចក្តីថ្លែងអំណរគុណ ------------------ ឃ

មាតិកា ------------------------------ ច

## ឱឃៈ ៤ ប្រការ

១_កាមោឃៈ ---------------------------- ២

_វត្ថុកាម -------------------------- ៣

_កិលេសកាម ------------------------ ៤

_កិលេសកាម ក្នុង អដ្ឋកថា ------------ ៥

_កិលេសកាម ១៥០០ -------------- ១៥

២_ភវោឃៈ អន្លង់គឺៈ ភព --------- ២៣

-កាមភព ------------------------------២៤

-រូបភព ------------------------------២៤

-អរូបភព ------------------------------២៥

-ជំពូករូបព្រហ្ម ១៦ ----------------២៥

-៤ជាន់ខាងចុងមាន ----------------២៦

-ព្រហ្មលោក ៩ -----------------------២៧

**៣-និស្សោយៈ អន្លង់ គឺទិដ្ឋិ** ----------២៨

-ទិដ្ឋិកថា ------------------------------២៩

-សេចក្ដីពិស្ដារនៃទិដ្ឋិ ៨ --------------៣២

-ការរួបរឹតគឺទិដ្ឋិមាន ១៨ យ៉ាង -------៤១

-ទិដ្ឋិ ១៦ យ៉ាង -----------------------៤៣

-មិច្ឆាទិដ្ឋិរបស់គ្រូទាំង ៦ -------------៤៤

៤_អវិជ្ជោឃៈ អន្លង់គឺ អវិជ្ជា ______៥៣

_អវិជ្ជាមាន ៨ យ៉ាង ________________៥៤

អំពីការឆ្លងអន្លង់ ___________________៦៤

ទេវទូតសូត្រ _____________________៧៩

ទេវទូតទី ១ ______________________៨៥

ទេវទូតទី ២ ______________________៨៨

ទេវទូតទី ៣ ______________________៩២

ទេវទូតទី ៤ ______________________៩៦

ទេវទូតទី ៥ _____________________១០២

# ឯកសារយោង

១.សុត្តន្តបិដក ទីឃនិកាយ សីលខន្ធវគ្គ ភាគ១៤

២.សុត្តន្តបិដក ទីឃនិកាយ បឋម ភាគ ១៧

៣.សុត្តន្តបិដក មជ្ឈិមនិកាយ មហាវរវគ្គ ភាគ១៩

៤.សុត្តន្តបិដក មជ្ឈិមនិកាយ ទុតិយ ភាគ ២១

៥.សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក អដ្ឋម ភាគ ២៧

៦.សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋម ភាគ ២៩

៧-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ តតិយ ភាគ ៣១

៨-សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ បញ្ចម ភាគ ៣៣

៩-សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ឆដ្ឋ ភាគ ៣៤

១០-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ទុតិយ ភាគ ៤១

១១-សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត អដ្ឋម ភាគ ៤៧

១២-សុត្តន្តបិដក ខុទ្ទកនិកាយ ភាគ ៦៧

១៣_សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស ទុតិយ ភាគ ៦៨

១៤_សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទុតិយ ភាគ ៧០

១៥_អភិធម្មបិដក ធម្មសង្គណី ភាគ ៧៩

១៦_អភិធម្មត្ថសង្គហៈ

១៧_ប្រាស្នាត្រៃគុណ

១៨_បញ្ញានិទ្ទេស

១៩_ប្រជុំកងធម៌អធិប្បាយថ្នាក់ទោភាគ ១_២

២០_គោលធម៌មធ្យមវិបស្សនា

២១_វចនានុក្រម សម្ដេច ជួន ណាត (ជ.ណ)

២២_បទានុក្រមបាលីភាគ ១_២_៣ ។

# ឱឃៈ ៤ ប្រការ

**នមត្ថុ រតនត្តយស្ស** សូមនមស្ការ ចំពោះព្រះរតនត្រ័យ(ដោយគោរព)។

លំដាប់ពីបទនមស្ការនេះទៅ សូមពណ៌នាអំពីពាក្យ **ឱឃៈ** ឬអន្លង់ ដូចមានសេចក្តីអធិប្បាយតទៅនេះ :

-**ឱឃៈ**[១] ឬអន្លង់ ប្រែថាៈ ការបៀតបៀនខាងទាប(អន្លង់ការប្រជុំ, សំទុះ ឬកំលាំង)

-ន័យមួយទៀត **ឱឃៈ** ប្រែថាៈ អន្លង់, ជំនន់, ទឹកដែលឡើងលិចជ្រៅ, កំលាំងខ្សែទឹក

---

[១] **ឱឃៈ ឬយោគៈ អាសវៈ** ក៏បាន។

ទឹកដែលហូរសំយុងចុះខ្លាំង សភាពនេះឯងហៅថា **ឱឃៈ** ដូចជាជំនន់ទឹក ព្រោះលិចសង្កត់ចិត្តរបស់សត្វគ្រប់រូប ឱឃៈនោះមាន ៤ ប្រការ។

## អន្លង់មាន ៤ គឺៈ

១_**កាមោឃៈ** អន្លង់គឺ កាម

២_**ភវោឃៈ** អន្លង់គឺ ភព

៣_**ទិដ្ឋោឃៈ** អន្លង់គឺ ទិដ្ឋិ

៤_**អវិជ្ជោឃៈ** អន្លង់គឺ សេចក្តីល្ងង់ខ្លៅ។

**១_កាមោឃៈ** ប្រែថាៈ សេចក្តីប្រាថ្នា, សេចក្តីចង់បាន, ចំណង់ សេចក្តីប្រាថ្នាជា

អន្លង់ ដូចវិគ្គហៈថា **កមនំ   បដ្ឋនំ > កាមោ**។

ពាក្យថា កាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ យ៉ាងគឺៈ វត្ថុកាម១ កិលេសកាម ១។

**~វត្ថុកាម** ក្នុងទីនេះបានដល់សេចក្តីប្រាថ្នា ចំពោះវត្ថុដែលជាអារម្មណ៍ខាងក្រៅដែល ជាគ្រឿងលួងចិត្ត នាំចិត្តឱ្យជាប់ជំពាក់ឱ្យញ៉ាម សំដៅយកកាមគុណទាំង៥ បានដល់រូបជាទីគាប់ចិត្ត សំលេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ

ឈ្មោល_ញី ស្រែចម្ការ ប្រាក់មាស ស្រុក និគមរាជធានី ដែនជនបទ សេនានិករ ឃ្លាំង វត្ថុជាទីតាំងនៃសេចក្តីត្រេកអរណាមួយ ឈ្មោះថា វត្ថុកាម។

‿**កិលេសកាម** គឺធម៌ជាគ្រឿងសៅហ្មង ដែលប្រឡាក់ ដែលប៉ះពាល់រូបរឹតចិត្ត ដូចវិគ្គហៈថា **កិលេស្សន្តិ តេហីតិ** > **កិលេសា** ហៅថា បរិយុដ្ឋានកិលេសរួមមាន

_**កាមឆន្ទះ** សេចក្តីជំពាក់ចិត្តក្នុងកាមទាំងឡាយ។

-**ព្យាបាទ** គំនុំគុំគួនព្យាបាទសត្វ និងសង្ខារ

_**ថីនមិទ្ធៈ** សេចក្តីធុញទ្រាន់ និងងងុយជ្រប់ ឬថាសេចក្តីច្រអូសកាយច្រអូសចិត្ត សភាពរួញរាចិត្ត។

_**ឧទ្ធច្ចកុក្កុច្ចៈ** សេចក្តីរាយមាយចិត្ត និងរំខានចិត្ត ឬសេចក្តីអណ្តែងអណ្តូងចិត្ត និងក្តៅក្រហាយចិត្ត។

_**វិចិកិច្ឆា** សេចក្តីសង្ស័យមិនអស់ មិនហើយ។

## អដ្ឋកថា ថាៈ

**-កាមឆន្ទៈ១** ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះសភាវៈ មិនទៀង ថាមិនទៀងមែន ទុក្ខ ថាទុក្ខមែន មិនមែនខ្លួន ថា

មិនមែនខ្លួនពិត ដូច្នេះ ជាហេតុលះបង់នូវកាមឆន្ទៈ។

មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺៈ

+កំណត់ ឬរៀននូវអសុភនិមិត្តគឺ អារម្មណ៍ថាមិនល្អ១។

+កិរិយាក្រេបករឿយៗ នូវការចំរើនអសុភ១

+ភាវៈជាអ្នកមានទ្វារគ្រប់គ្រងល្អ ក្នុងឥន្ទ្រិយទាំងប្រាំមួយ ១។

+ភាវៈជាអ្នកដឹងប្រមាណក្នុងការបរិភោគភោជន១។

+ភាវៈជាអ្នករាប់រកនូវកល្យាណមិត្ត១។

+ភាវៈជាអ្នករៀន ឬនិយាយតែពាក្យដែល

ជាទីសប្បាយ១។

-**កាមឆន្ទៈ២** មិនកើតតទៅទៀត ដោយសារ អរហត្តមគ្គ។

-**ព្យាបាទៈ១** ការធ្វើទុកក្នុងចិត្តដោយឧបាយ ប្រាជ្ញាចំពោះបដិឃៈនិមិត្ត គឺអារម្មណ៍ដែល ខ្ទាំងខ្ទប់ចិត្ត ជាហេតុនាំឱ្យកើតព្យាបាទ។

-**ព្យាបាទៈ២** ការធ្វើទុកក្នុងចិត្តដោយឧបាយ ប្រាជ្ញាចំពោះមេត្តាចេតោវិមុត្តិ គឺមេត្តាចិត្ត ដែលបានអប្បនាឈាន ជាហេតុឱ្យលះបង់នូវ ព្យាបាទបាន។

មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺ

+រៀនមេត្តានិមិត្ត១

+កិរិយាប្រកបរឿយៗ នូវការចម្រើន

មេត្តា១។

+ពិចារណាឃើញនូវភាវៈនៃសត្វដែល

មានកម្មជារបស់ខ្លួន១។

+ភាវៈជាអ្នកច្រើនដោយការពិចារណា១។

+ភាវៈជាអ្នករាប់រកនូវកល្យាណមិត្ត១។

+ភាវៈជាអ្នកនិយាយតែពាក្យដែល ជាទី

សប្បាយ១។

**-ព្យាបាទៈ៣** មិនកើតតទៅទៀតដោយសារ

អនាគាមិមគ្គ។

**-ថីនមិទ្ធៈ១** ហេតុដែលនាំឱ្យកើតថីនមិទ្ធៈ

មាន ៥ ប្រការគឺ :

+មិនត្រេកអរ១

+ច្រអូស ឬទម្រន់កាយ១

+មិនពត់កាយ១

+ពុលបាយ១

+រួញចិត្ត១

**-ថីនមិទ្ធៈ២** ហេតុដែលលះបង់ថីនមិទ្ធៈដោយ

ព្យាយាម ៣ យ៉ាងគឺ

+ព្យាយាមដែលប្រារព្ធផ្ដើមឡើងជាដំបូង១

+ព្យាយាមយ៉ាងកណ្ដាល ជាគ្រឿងចេញ

ចាកកោសជ្ជៈ (សេចក្ដីខ្ជិល១)។

+ព្យាយាមយ៉ាងក្រៃលែង ដែលកន្លងរួចចាកកោសជ្ជៈ១។

ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺៈ

-កាន់យកនិមិត្តក្នុងការបរិភោគហួសប្រមាណ១

-ភាពនៃកិរិយាផ្លាស់ប្តូរឥរិយាបថ១

-ការធ្វើទុកក្នុងចិត្តចំពោះអាលោកសញ្ញា១

-នៅក្នុងឱកាសដែលស្រឡះ១

-ភាពជាអ្នករាប់រកនូវកល្យាណមិត្ត១

-ភាពជាអ្នកនិយាយនូវពាក្យជាទីសប្បាយ១

**-ថីនមិទ្ធៈ៣** មិនកើតតទៅទៀត ដោយសារអរហត្តមគ្គ។

**-ឧទ្ធច្ចកុក្កុច្ចៈ១** ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញាចំពោះធម៌ដែលមិនមែនជាគ្រឿងរម្ងាប់ចិត្ត ជាហេតុនាំឱ្យកើតឧទ្ធច្ចកុក្កុច្ចៈ។

**-ឧទ្ធច្ចកុក្កុច្ចៈ២** ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះធម៌ដែលជាគ្រឿងរម្ងាប់ចិត្ត ជាហេតុលះបង់នូវឧទ្ធច្ចកុក្កុច្ចៈបាន។

មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺៈ

+ភាវៈជាអ្នកចេះដឹង ឬស្តាប់ច្រើន១

+ភាវៈជាអ្នកឧស្សាហ៍សាកសួរ១

+ភាវៈជាអ្នកចេះដឹងស្ទាត់ក្នុងវិន័យ១

+ភាវៈជាអ្នកសេពនូវបុគ្គលដែលចម្រើន១

+ភាវៈជាអ្នករាប់រកកល្យាណមិត្ត១

+ភាវៈជាអ្នកនិយាយនូវពាក្យដែលជាទីសប្បាយ១។

**៣-ឧទ្ធច្ចៈ** មិនកើតតទៅទៀត ដោយសារអរហត្តមគ្គ។ ឯ **កុក្កុច្ចៈ** មិនកើតទៅទៀតដោយសារអនាគាមិមគ្គ។

**-ឧទ្ធច្ចកុក្កុច្ចៈ៤** ការធ្វើទុកក្នុងចិត្តដោយឥត ឧបាយប្រាជ្ញាចំពោះធម៌ដែលជាទីតាំង នៃសេចក្ដីសង្ស័យជាហេតុនាំឱ្យកើតវិចិកិច្ឆា។

**-វិចិកិច្ឆា១** ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះកុសលធម៌ជាដើម ជាហេតុឱ្យលះបង់នូវវិចិកិច្ឆាបាន។

មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺៈ

+ភាវៈជាអ្នកចេះដឹង ឬស្តាប់ច្រើន១

+ភាវៈជាអ្នកឧស្សាហ៍សាកសួរ១

+ភាវៈជាអ្នកចេះដឹងស្ទាត់វិន័យ១

+ភាវៈជាអ្នកច្រើនទៅដោយចិត្តដែលជឿ

ស៊ប់១

+ភាវៈជាអ្នករាប់រកកល្យាណមិត្ត១

+ជាអ្នកនិយាយនូវពាក្យជាទីសប្បាយ១។

**-វិចិកិច្ឆា២** មិនកើតទៅទៀត ដោយសារសោ

តាបត្តិមគ្គ។

-សេចក្តីសៅហ្មងដែលដេកនៅរឿយៗ

ក្នុងសន្តានហៅថា អនុសយក្កិលេស គឺសេច

ក្តីសៅហ្មងដែលដេកនៅរឿយ នៅក្នុង សន្តាន ឬថាកិលេសដែលអាស្រ័យនៅក្នុង ចិត្តរឿយៗ បានដល់កិលេសដ៏ល្អិត ដែល ហៅថា អនុសយក្កិលេសរួមមាន :

១. **កាមរាគះ** តម្រេកក្នុងកាម

២. **បដិឃះ** សេចក្តីថ្នាំងថ្នាក់ចិត្ត

៣. **ទិដ្ឋិ** សេចក្តីយល់ឃើញ

៤. **វិចិកិច្ឆា** សេចក្តីសង្ស័យ

៥. **មានះ** សេចក្តីប្រកាន់រឹងត្អឹង

៦. **ភវរាគះ** តម្រេកក្នុងភព

៧. **អវិជ្ជា** សេចក្តីងងឹតងងុល

**កិលេសកាម** បើដោយសេចក្ដីពិស្ដារ មានរហូតដល់ **១៥០០** កិលេស គឺ កិលេសជាគ្រឿងមន្ទិល ៣ គឺៈ **រាគៈ១ ទោសៈ១ មោហៈ១** ។

-អាសវៈ ៣គឺៈ កាមាសវៈ១, ទិដ្ឋាសវៈ១ អវិជ្ជាសវៈ១។

-វិបល្លាស ៣គឺៈ សញ្ញាវិបល្លាស១, ចិត្តវិបល្លាស១, ទិដ្ឋិវិបល្លាស១។

-អនុសយៈ ៣គឺៈ កាមរាគានុសយៈ១, ទិដ្ឋានុសយៈ១, អវិជ្ជានុសយៈ១។

-អគតិ ៤គឺៈ ឆន្ទាគតិ១, ទោសាគតិ១, មោហាគតិ១, ភយាគតិ១។

-គន្ថៈ ៤គឺៈ អភិជ្ឈាកាយគន្ថៈ១, ព្យាបាទកាយគន្ថៈ១, សីលព្វត្តបរាមាសកាយគន្ថៈ១, ឥទំសច្ចាភិនិវេសកាយគន្ថៈ១។

-ឱឃៈ ៤គឺៈ កាមោឃៈ១, ភវោឃៈ១, ទិដ្ឋោឃៈ១, អវិជ្ជោឃៈ១។

-ឧបាទាន ៤គឺៈ កាមុបាទានៈ១, ទិដ្ឋុបាទានៈ១, សីលព្វត្តុបាទានៈ១,អត្តវាទុបាទានៈ១

-មច្ឆរិយៈ៥គឺៈ អាវាសៈមច្ឆរិយៈ១, កុសលមច្ឆរិយៈ១, វណ្ណមច្ឆរិយៈ១, លាភមច្ឆរិយៈ១, ធម្មមច្ឆរិយៈ១។

-អនុសយៈ ៧គឺៈ កាមរាគនុសយៈ១, ភវរាគៈនុសយៈ១, បដិឃានុសយៈ១, មានានុ-

សយៈ១, ទិដ្ឋានុសយៈ១, វិចិកិច្ឆានុសយៈ១, អវិជ្ជានុសយៈ១។

_លោកធម៌ ៨គឺៈ ១.**លោភោ** បានលាភ, ២_**អលោភោ** មិនបានលាភ, ៣_**យសោ** បានយស, ៤_**អយសោ** មិនបានយស, ៥_**សុខំ** បានសុខ, ៦_**ទុក្ខំ** បានទុក្ខ, ៧_**និន្ទា** ត្រិះដៀល ៨_**បសំសា** សរសើរ។

_**មលៈ** ធម៌ជាមន្ទិល ៩គឺៈ **កោធៈ** ក្រោធ១ **មក្ខៈ** រមិលគុណគេ១, **ឥស្សា** សេចក្តីប្រណែនឈ្នានីសគេ១, **មច្ឆរិយៈ** កំណាញ់១, **មាយា** ការលាក់ពុធត្បត់១, **សាថេយ្យ** ការពោលអួត

អាង១, **មុសា** ការពោលកុហក១, **បាបិច្ឆះ** ការប្រាថ្នាអាក្រក់១, **មិច្ឆាទិដ្ឋិ** ឃើញខុស១។

-អកុសលកម្មបថ ១០ ។

-សំយោជនៈ ១០គឺៈ **សក្កាយទិដ្ឋិ** ប្រកាន់កាយថាជារបស់ខ្លួន១, **វិចិកិច្ឆា** សេចក្ដីសង្ស័យស្ទាក់ស្ទើរ១, **សីលព្វតួបរាមាសៈ** ការស្ទាប់អង្អែលដោយសីល និងវត្តខាងក្រៅព្រះពុទ្ធសាសនា១, **កាមរាគៈ** សេចក្ដីត្រេកអរក្នុងកាម១, **បដិឃៈ** សេចក្ដីថ្នាំងថ្នាក់ចិត្ត១, **រូបរាគៈ** សេចក្ដីត្រេកអរក្នុងរូបភព១, **អរូបរាគៈ** សេចក្ដីត្រេកអរក្នុងអរូបភព១, **មានោ** សេច

ក្ដីប្រកាន់១, **ឧទ្ធច្ចៈ** ចិត្តអណ្ដែតអណ្ដូងរាយមាយ១, **អវិជ្ជា** សេចក្ដីល្ងង់ខ្លៅ១។

-កិលេស ១០គឺៈ **លោភោ** សភាពធ្វើចិត្តឱ្យជាប់ជំពាក់នូវក្នុងអារម្មណ៍១, **ទោសោ** សភាពធ្វើចិត្តឱ្យប្រទូស្តក្នុងអារម្មណ៍ ឬថ្នាំងថ្នាក់១, **មោហោ** សភាពធ្វើចិត្តឱ្យវង្វេងក្នុងអារម្មណ៍១, **មានោ** សភាពលើកខ្លួន ឬដាក់ខ្លួន១, **ទិដ្ឋិ** ធម្មជាតិធ្វើចិត្តឱ្យឃើញខុស ឬយល់ខុស១, **វិចិកិច្ឆា** ធម្មជាតិឱ្យសង្ស័យ ឬស្ទាក់ស្ទើរ១, **ថីនំ** ធម្មជាតិធ្វើចិត្តឱ្យរួញរា ឬឱ្យធុញទ្រាន់ក្នុងកុសលផ្សេងៗ១, **ឧទ្ធច្ចំ** ធម្ម

ជាតិធ្វើចិត្តឱ្យញាប់ញ័រ ឬរាយមាយ១, **អហិរិកំ** ធម្មជាតិមិនខ្មើមអំពើទុច្ចរិត១, **អនោត្តប្បំ** ធម្មជាតិមិនខ្លាច ឬមិនតក់ស្លុតនិងអំពើទុច្ចរិត១

_មិច្ឆត្តធម៌ ១០គឺ: ១.**មិច្ឆាទិដ្ឋិ** គំនិតយល់ខុសហើយប្រកាន់ថាត្រូវ, ២.**មិច្ឆាសង្កប្ប** ត្រិះរិះខុស, ៣.**មិច្ឆាវាចា** សំដីខុស, ៤.**មិច្ឆាកម្មន្តៈ** ការងារខុស, ៥.**មិច្ឆាអាជីវៈ** ចិញ្ចឹមជីវិតខុស, ៦.**មិច្ឆាវាយាមៈ** ព្យាយាមខុស, ៧.**មិច្ឆាសតិ** រលឹកខុស, ៨.**មិច្ឆាសមាធិ** ដម្កល់ចិត្តខុស, ៩.**មិច្ឆាវិមុត្តិ** ការរួចខុស, ១០.**មិច្ឆាញាណៈ** ការដឹងខុស។

-**អកុសលចិត្តុប្បាទ** ១២គឺៈ លោភមូល៨, ទោសមូល២, មោហមូល២ ត្រូវជា ១២។

-**តណ្ហា** ១០៨ ចែកដូច្នេះគឺៈ តណ្ហាខាងក្នុង ១៨ ចែកតាមអាយតនៈខាងក្រៅ ៦គឺៈ រូបតណ្ហា១ សទ្ទតណ្ហា១ គន្ធតណ្ហា១ រសតណ្ហា១ ផោដ្ឋព្វតណ្ហា១ ធម្មតណ្ហា១ ក្នុងអាយតនៈមួយៗ ចែកជាបីៗគឺៈ កាមតណ្ហា១, ភវតណ្ហា១, វិភវតណ្ហា១, ៣ គុណ ៦ ត្រូវជា ១៨។

តណ្ហាខាងក្នុង ១៨ ចែកតាមអាយតនៈខាងក្នុង ៦ គឺៈ ចក្ខុ១ សោតៈ១ ឃានៈ១ ជីវ្ហា១ កាយ១ ចិត្ត១ ក្នុងអាយតនៈមួយៗ

ចែកជា បី១គឺៈ កាមតណ្ហា១, ភវតណ្ហា១, វិភវតណ្ហា ១, ៣ គុណ ៦ ត្រូវជា ១៨។ ១៨ ខាងក្រៅ បូក ១៨ ខាងក្នុង ស្មើ ៣៦។ ចាត់ជាអតីតៈ ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមត្រូវជា ១០៨។

ម្យ៉ាងទៀតកិលេសនេះ បើពោលទៅតាមន័យដែលបៀតបៀនសត្វឱ្យលិចលង់ក្នុងកាមមោឃៈ បានដល់កិលេសមារ ១៥០០ គឺៈ រាប់យកលោកិយចិត្ត ៨១ ថា ១ យកចេតសិក ៥២[២] មកផ្សំជា ៥៣ យកនិប្ផន្នរូប ១៨

---

[២] អភិធម្មត្ថសង្គហ

មកផ្សំជា ៧១ យកអាកាស១ ជាតិ១ ជរា១ ភវង្គ១ មកផ្សំជា ៧៥ ចាត់ជាកិលេសខាងក្នុង ៧៥ ខាងក្រៅ ៧៥ ផ្សំជាមួយគ្នាជាកិលេស ១៥០ ហើយកិលេស ១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនមិទ្ធៈ អហិរិកៈ អនោត្តប្ប និងឧទ្ធច្ចៈ មកគុណនិងកិលេស ១៥០ ត្រូវជាកិលេស ១៥០០។

## ២_ភវោឃៈ អន្លង់ គឺៈ ភព

ពាក្យថា **ភព** សំដៅយកទីលំនៅជាទីកើតឬទីជាដែនកើតនៃពពួកសត្វ។ ភពនោះមាន ៣ យ៉ាងគឺ កាមភព១, រូបភព១, អរូបភព១។

**កាមភព** គឺភពជាកាមាវចរ មាន ១១ ជាន់ ហើយចែកចេញជា ៣ ប្រភេទគឺ អបាយភូមិ ៤: នរក១, ប្រេត១, អសុរកាយ១, តិរច្ឆាន១។ ឋានមនុស្ស១ និងឋានសួគ៌៦ជាន់ ចាតុមហារាជិកា១, តាវតឹង្ស១, យាមា១, តុសិត ១, និម្មានរតី១, បរនិម្មិតវសវត្តី១។

**រូបភព** គឺភពជារូបាវចរ បានដល់រូបព្រហ្ម ១៦ ជាន់ : ព្រហ្មបារិសជ្ជា១, ព្រហ្មបុរោហិតា១, មហាព្រហ្មា១, បរិត្តាភា១, អប្បមាណាភា១, អាភស្សរា១, បរិត្តសុភា១, អប្ប-មាណសុភា១, សុភកិណ្ហា១, វេហប្ផលា១,

អសញ្ញិសត្តា១, អវិហា១, អតប្បា១, សុទស្សា១, សុទស្សី១, អកនិដ្ឋា១។

**អរូបភព** គឺភពជាអរូបាវចរ បានដល់ព្រហ្មដែលមិនមានរូប ៤ ជាន់មាន អាកាសានញ្ចាយតនៈ១, វិញ្ញាណញ្ចាយតនៈ១, អាកិញ្ចញ្ញាយតនៈ១, នេវសញ្ញានាសញ្ញាយតនៈ១។

**ជំពូករូប**ព្រហ្ម ១៦ ជាន់នោះ កើតដោយរូបជ្ឈាន ៤ ចាត់ដូចនេះគឺ ៣ជាន់ខាងដើម បានដល់

- ព្រហ្មបារិសជ្ជា១
ព្រហ្មបរោហិតា១ } ជាជាន់បឋមជ្ឈាន។
មហាព្រហ្មា១

- ជាន់បរិត្តាភា១<br>អប្បណាភា១<br>អាភស្សរា១ } ជាជាន់ទុតិយជ្ឈាន។

- ជាន់បរិត្តាសុភា១<br>អប្បមាណសុភា១<br>សុភកិណ្ហា១ } ជាជាន់តតិយជ្ឈាន។

៧ ជាន់ទៀតគឺ :

អសញ្ញី១, វេហប្ផលា១, អវិហារ១, អតប្បា១ សុទស្សា១, សុទស្សី១, អកនិដ្ឋិកា១ ជាជាន់ចតុត្ថជ្ឈាន។

-៤ ជាន់ខាងចុងមាន អាកាសានញ្ចាយតនៈ១, វិញ្ញាណញ្ចាយតនៈ១, អាកិញ្ចញ្ញា

យតនៈ១, នេវសញ្ញានាសញ្ញាយតនៈ១ ជាជាន់អរូបជ្ឈាន។

-និងព្រហ្មលោក ៩ ជាន់គឺៈ សុទ្ធាវាស ៥ បានដល់ជាន់ អវិហា១, អតប្បា១, សុទស្សា ១, សុទស្សី១, អកនិដ្ឋា១ និងអរូបព្រហ្ម ៤ មានអាកាសានញ្ចាយតនៈជាដើម ជាទីកើតរបស់ព្រះអានាគាមិបុគ្គល។

-ចំណែកព្រះអរិយជាន់ ព្រះសោតា, សកទាគាមី បើកើតក្នុងជាន់រូបព្រហ្មហើយមិនត្រឡប់ចុះមកកើតក្នុងមនុស្សលោកនេះទៀតទេ។

ភពទាំង ៣ នេះ មានអវិជ្ជា តណ្ហា ឧបាទាន ជាបច្ច័យឱ្យកើតត១ ដឹកនាំសត្វឱ្យទៅកាន់សេចក្ដីវិនាស មានកិរិយាកើត ចាស់ ឈឺ ស្លាប់ប្រព្រឹត្តិទៅក្នុងសង្សារទុក្ខ។

**៣~និវោ្ធាយៈ អន្លង់ គឺទិដ្ឋិ** សំដៅយកមិច្ឆាទិដ្ឋិ។

ពាក្យថា មិច្ឆាទិដ្ឋិនេះ ចែកចេញជា ២ បទគឺ **មិច្ឆា + ទិដ្ឋិ = មិច្ឆាទិដ្ឋិ**

**មិច្ឆា** ប្រែថា ខុស, **ទិដ្ឋិ** ប្រែថា កិរិយាឃើញ, ការយល់ឃើញ។ រួមសេចក្ដីមក **មិច្ឆាទិដ្ឋ** ប្រែថា កិរិយាឃើញខុស, ការយល់ឃើញខុស,

សេចក្ដីយល់ខុស។ ដូចវិគ្គហៈថា **មិច្ឆាទស្សនំ** > **មិច្ឆាទិដ្ឋិ** ។

# **ទិដ្ឋិកថា**

ហេតុនៃទិដ្ឋិ[៣] មាន ៨ យ៉ាង គឺៈ

+**ខន្ធ** ជាហេតុនៃទិដ្ឋិ១, **អវិជ្ជា** ជាហេតុនៃទិដ្ឋិ១, **ផស្សៈ** ជាហេតុនៃទិដ្ឋិ១, **សញ្ញា** ជាហេតុនៃទិដ្ឋិ១, **វិតក្កៈ** ជាហេតុនៃទិដ្ឋិ១, **អយោនិសោមនសិការៈ** ជាហេតុនៃទិដ្ឋិ១, **បាបមិត្ត** ជាហេតុនៃទិដ្ឋិ១, **បរតោឃោសៈ** (សំដៅយកឃោសនារបស់បុគ្គលដទៃ) ជាហេតុនៃទិដ្ឋិ១។

---

[៣] ហេតុនាំឱ្យកើតទិដ្ឋិ ។

-**ខន្ធ** ជាហេតុ ខន្ធជាបច្ច័យដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ ខន្ធ ឈ្មោះថាជាហេតុនៃទិដ្ឋិយ៉ាងនេះ១

-**អវិជ្ជា** ជាហេតុ អវិជ្ជាជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ អវិជ្ជាឈ្មោះហេតុនៃទិដ្ឋិយ៉ាងនេះ១។

-**ផស្សៈ** ជាហេតុ ផស្សជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យហេតុនៃទិដ្ឋិ ផស្សៈ ឈ្មោះថាហេតុនៃទិដ្ឋិយ៉ាងនេះ១។

-**សញ្ញា** ជាហេតុ សញ្ញាជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យហេតុនៃទិដ្ឋិ

សញ្ញា ឈ្មោះថាហេតុនៃទិដ្ឋិយ៉ាងនេះ១។

‿**វិតក្កៈ** ជាហេតុ វិតក្កៈជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ វិតក្កៈ ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ១

‿**អយោនិសោមនសិការៈ** ជាហេតុ អយោនិសោមនសិការៈជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ អយោនិសោមនសិការៈ ឈ្មោះថាជាហេតុនៃទិដ្ឋិយ៉ាងនេះ១។

‿**បាបមិត្ត** ជាហេតុ បាបមិត្តជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យ

នូវហេតុនៃទិដ្ឋិ បាបមិត្ត ឈ្មោះថាហេតុនៃទិដ្ឋិយ៉ាងនេះ១។

**៉បរតោឃោសះ** (សំដីឃោសនានៃបុគ្គលដទៃ) ជាហេតុ បរតោឃោសះជាបច្ច័យដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ បរតោឃោសះ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ១។ នេះហេតុនៃទិដ្ឋិ ៨ យ៉ាង ។

## សេចក្តីពិស្តារនៃទិដ្ឋិ ៨

ពាក្យថា **ខន្ធ** សំដៅយកខន្ធ៥ ដែលបញ្ញត្តិមានសត្វ បុគ្គល ស្រី ប្រុស គេ យើង ព្រោះ

មនុស្សយើងច្រើនពុំសូវមានសតិសម្បជញ្ញៈ កំណត់ដឹងនូវបញ្ចក្ខន្ធ តាមសេចក្តីដូចព្រះអរិយបុគ្គល។ កាលបើក្រឡេកឃើញអ្វីៗ ច្រើនតែសំគាល់ថាមានសត្វ បុគ្គល ទ្រព្យសម្បត្តិ មាស ប្រាក់ ឬការព្យសំលេងតាមការដឹងក្លិន តាមការដឹងរស តាមការដឹងផោដ្ឋព្វៈ និងតាមការដឹងធម្មៈ ក៏សុទ្ធតែយើងគេទាំងអស់ ធ្វើឱ្យជាប់ចិត្ត ប្រកាន់យកនូវអារម្មណ៍នោះថា ជារបស់ខ្លួន (ទិដ្ឋិ) ដូច្នោះ ខន្ធជាហេតុ ខន្ធជាបច្ច័យដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។

ពាក្យថា **អវិជ្ជា** ជាឈ្មោះនៃការមិនដឹងទុក្ខ **ទុក្ខេ អញ្ញាណំ** មិនដឹងហេតុនៃសេចក្តីទុក្ខ **ទុក្ខ សមុទយេ អញ្ញាណំ** មិនដឹងការរលត់ទុក្ខ **ទុក្ខ និរោធេអញ្ញាណំ** មិនដឹងផ្លូវទៅកាន់ទីរលត់ទុក្ខ **ទុក្ខ និរោធគាមិនីបដិបទា អញ្ញាណំ** របស់អរិយសច្ចៈទាំង ៤ និងជាប្រធាននៃអកុសលធម៌ទាំងឡាយ មានតណ្ហាទិដ្ឋិ មានៈជាដើម ព្រមទាំងធម៌តាក់តែងនូវអភិសង្ខារក្នុងបដិច្ចសមុប្បាទធម៌ ដូច្នោះ អវិជ្ជាជាហេតុ អវិជ្ជាជាបច្ច័យ ដោយអត្ថថា

តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។

ពាក្យថា **ផស្សៈ** ជាពួកសព្វចិត្តសាធារណៈចេតសិក ៧ នៅក្នុងអញ្ញសមានាចេតសិក ១៣ ជាចេតសិកសម្រាប់តាក់តែងចិត្តឱ្យល្អ ឬអាក្រក់ទៅតាមចិត្តកើតឡើងនោះឯង។ ផស្សៈជាទីប្រជុំនៃធម៌ ៣ ព្រោះអាស្រ័យចិត្ត និងធម៌ ទើបមនោវិញ្ញាណកើតឡើង ប្រៀបដូចជាមុមចង្ក្រានមាន ៣ បើខ្វះធម៌ណាមួយ ឬលើសពីនេះ មិនហៅថា ផស្សៈ ដូចវេទនា សោយអារម្មណ៍ជាទុក្ខ ឬជាសុខ ព្រោះផស្សៈជាបច្ច័យ ដូច្នោះ ផស្សៈជាហេតុ

ផស្សៈជាបច្ច័យដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។

ពាក្យថា **សញ្ញា** ជាចេតសិកកើតនៅក្នុងពួកសព្វចិត្តសាធារណៈចេតសិក ៧ មានកិច្ចសម្រាប់សំគាល់ ឬចំណាំនូវអារម្មណ៍គឺ កំណត់ដឹងនូវអាការៈគ្រឿងសម្គាល់នូវលក្ខណៈផ្សេងៗ ដែលជាហេតុធ្វើឱ្យចាំអារម្មណ៍បាន ដូច្នោះសញ្ញាជាហេតុ សញ្ញាជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។

ពាក្យថា **វិតក្កៈ** ជាពួកចេតសិកនៅក្នុងបកិណ្ណកចេតសិក ៦ មានតួនាទីសម្រាប់ត្រិះ

រិះនូវអារម្មណ៍ផ្សេងៗ ទុកជាជំនួយដល់ទិដ្ឋិនោះៗ និងជាការត្រាច់ទៅរបស់សត្វទាំងឡាយ ដូច្នោះ វិតក្កៈជាហេតុ វិតក្កៈជាបច្ច័យដោយអត្ថថាៈ តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។ នៅក្នុងខុទ្ទកនិកាយ ចូឡ-និទ្ទេស សុត្តន្តបិដក ទុតិយភាគ លេខ ៦៨ ទំព័រ១៦ ទ្រង់សម្ដែងពីសេចក្ដីត្រិះរិះមាន ៩ យ៉ាង

១-**កាមវិតក្កោ** សេចក្ដីត្រិះរិះក្នុងកាម

២-**ព្យាបាទវិតក្កោ** សេចក្ដីត្រិះរិះក្នុងការធ្វើឱ្យវិនាស

៣_**វិហើសារិតក្កោ** សេចក្តីត្រិះរិះក្នុងការរៀនការបៀន

បៀតបៀន

៤_**ញាតិវិតក្កោ** សេចក្តីត្រិះរិះក្នុងញាតិ

៥_**ជនបទវិតក្កោ** សេចក្តីត្រិះរិះក្នុងជនបទ

៦_**អមរវិតក្កោ** សេចក្តីត្រិះរិះក្នុងការមិនស្លាប់

៧_**បរានុទ្ទយតាបដិសំយុត្តោវិតក្កោ** សេចក្តីត្រិះរិះដោយភាពនៃការអាណិតដល់ជនដទៃ

៨_**លាភសក្ការសិលោកប្បដិសំយុត្តោវិតក្កោ** សេចក្តីត្រិះរិះចំពោះលាភសក្ការៈ និងការសរសើរ

៩_**អនវញ្ញត្តិប្បដិសំយុត្តោរិតក្កោ** សេចក្ដីត្រិះរិះប្រកបដោយការមិនចង់ឱ្យគេមើលងាយ។ នេះជាសេចក្ដីត្រិះរិះ ជាគ្រឿងត្រាច់ទៅរបស់សត្វទាំងឡាយមាន៩ យ៉ាងដូច្នោះឯង។

ពាក្យថា **អយោនិសោមនសិការះ** ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង (ខ្វះបញ្ញា) ជាជំនួយដល់ទិដ្ឋិដូចគ្នា ដូច្នោះ អយោនិសោមនសិការះជាហេតុ អយោនិ-សោមនសិការះជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យហេតុនៃទិដ្ឋិ។

ពាក្យថា **បាបមិត្ត** សំដៅដល់មិត្តដែលចូលចិត្តសាងអំពើបាបផ្សេងៗ សន្សំទុកក្នុងខ្លួន ដូច្នោះ បាបមិត្តជាហេតុ បាបមិត្តជាបច្ច័យ ដោយអត្ថថា: តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុ នៃទិដ្ឋិ។

ពាក្យថា **បរតោឃោសៈ** ជាសំឡេងឃោសនារបស់បុគ្គលដទៃពីខាងក្រៅ ដូច្នោះ **បរតោឃោសៈ** ជាហេតុ **បរតោឃោសៈ** ជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ។

# ការរួបរឹតគឺទិដ្ឋិមាន ១៨ យ៉ាង

នៅក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទុតិយភាគ បិដកលេខ៧០ ទំព័រ១១ ទ្រង់សម្តែងថា

១_ដំណើរ គឺ ទិដ្ឋិ

២_ការប្រកាន់ គឺ ទិដ្ឋិ

៣_ផ្លូវកន្តារៈ គឺ ទិដ្ឋិ

៤_ចម្រូង គឺ ទិដ្ឋិ

៥_ការវិបត្តិ គឺ ទិដ្ឋិ

៦_សំយោជនៈ គឺ ទិដ្ឋិ

៧_សរ គឺ ទិដ្ឋិ

៨_ការចង្អៀតចិត្ត គឺ ទិដ្ឋិ

៩_ការកង្វល់ គឺ ទិដ្ឋិ

១០_ចំណោង គឺ ទិដ្ឋិ

១១_ជ្រោះ គឺ ទិដ្ឋិ

១២_អនុស័យ គឺ ទិដ្ឋិ

១៣_កម្តៅ គឺ ទិដ្ឋិ

១៤_ការក្រហល់ក្រហាយ គឺ ទិដ្ឋិ

១៥_គ្រឿងចាក់ស្រេះ គឺ ទិដ្ឋិ

១៦_គ្រឿងប្រកាន់ គឺ ទិដ្ឋិ

១៧_ការប្រកាន់ស្អិត គឺ ទិដ្ឋិ

១៨_ការស្ទាប់អង្អែល គឺ ទិដ្ឋិ ។

# ទិដ្ឋិ ១៦ យ៉ាង

**អស្សាទទិដ្ឋិ** (សេចក្ដីត្រេកអរ)១, **អត្តានុទិដ្ឋិ១**, **មិច្ឆាទិដ្ឋិ១**, **សក្កាយទិដ្ឋិ១**, **សក្កាយវត្ថុកសស្សតទិដ្ឋិ១**, **សក្កាយវត្ថុកឧច្ឆេទទិដ្ឋិ១**, **អន្តគ្គាហិកទិដ្ឋិ១**, **បុព្វន្តានុសទិដ្ឋិ១**, **អបរន្តានុទិដ្ឋិ១**, **សញ្ញោជនិតទិដ្ឋិ១**, **ទិដ្ឋ**ដែលជាប់ដោយមានះថាអញ១, **ទិដ្ឋ**ដែលជាប់ដោយមានះរបស់អញ១, **អត្តវាទប្បដិសំយុត្តទិដ្ឋិ១**, **លោកវាទប្បដិសំយុត្តទិដ្ឋិ១**, **ភវទិដ្ឋិ១**, **វិភវទិដ្ឋិ១**។

# មិច្ឆាទិដ្ឋិរបស់គ្រូទាំង ៦

**១-គ្រូឈ្មោះបូរណកស្សប** បានពោលពាក្យយ៉ាងនេះថា ហេតុ ឬបច្ច័យដែលនាំឱ្យសត្វទាំងឡាយសៅហ្មងមិនមានឡើយ សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យនាំឱ្យសៅហ្មងទេ ទាំងហេតុឬបច្ច័យដែលនាំឱ្យសត្វទាំងឡាយបរិសុទ្ធក៏មិនមាន សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ នាំឱ្យបរិសុទ្ធឡើយ (ស្រង់ចាកសំយុត្តនិកាយ ខន្ធវារវគ្គ បិដកលេខ ៣៣ ទំព័រ ១៦១)។ ចំណែកក្នុងទីឃនិកាយ សីលខន្ធវគ្គ បិដកលេខ១៤ ទំព័រ

១២៨ គ្រូបូរណកស្សបបានពោលថា អំពើដែលធ្វើជាបាប ជាបុណ្យមិនមានផលជាអកិរិយាវាទ (ពោលឃាតអំពើបុណ្យ-បាប)។

**២-គ្រូឈ្មោះមក្ខលិគោសាល** ពោលថា ហេតុប្បច្ច័យនាំឱ្យសៅហ្មង ដល់សត្វទាំងឡាយមិនមានទេ សត្វទាំងឡាយរមែងសៅហ្មងដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យនាំឱ្យបរិសុទ្ធដល់សត្វទាំងឡាយ មិនមានឡើយ សត្វទាំងឡាយរមែងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ អំពើរបស់ខ្លួនក៏មិនមាន អំពើរបស់អ្នកដទៃក៏មិនមាន (ដកស្រង់ពីក្នុង

ព្រហ្មជាលសូត្រ ទីឃនិកាយ សីលខន្ធវគ្គ បិដកលេខ ១៤ ទំព័រ១៣០)។

**៣-គ្រូឈ្មោះអជិតកេសកម្ពល** ពោលថា ទានដែលបុគ្គលឱ្យហើយ មិនមានផល១, ការបូជាធំមិនមានផល១, ការបូជាតូចមិនមានផល១, ផលនិងវិបាកនៃកម្មដែលបុគ្គលធ្វើល្អ ឬអាក្រក់មិនមានឡើយ១, ការប្រតិបត្តិខុស ឬត្រូវក្នុងមាតាមិនមានផល (បុណ្យបាប)១, ការប្រតិបត្តិខុស ឬត្រូវក្នុងបិតាមិនមានផល (បុណ្យ-បាប)១, សត្វជាឧបបាតិកៈកំណើតមិនមាន១, សមណនិងព្រាហ្មណ៍ទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា

ប្រតិបត្តិដោយប្រពៃ ធ្វើឱ្យជាក់ច្បាស់ ព្រោះត្រាស់ដឹងដោយខ្លួនឯង ហើយសម្តែងនូវលោកនេះ និងលោកខាងមុខ ក៏មិនមានក្នុងលោកឡើយ១។

**៤-គ្រូឈ្មោះបកុធកច្ចាយនះ** ពោលថា កាយទាំង ៧ គឺ: ពួកធាតុដី១,ពួកធាតុទឹក១, ពួកធាតុភ្លើង១, ពួកធាតុខ្យល់១, សេចក្តីទុក្ខ១, សេចក្តីសុខ១, ជីវិត១, កាយទាំងអស់នេះគ្មាននណារធ្វើកើត គ្មានវិធីធ្វើកើត គ្មាននណារនិម្មិតដោយឫទ្ធិបាន គ្មាននណារសាងកើត ជាសភាវៈអា តាំងនៅដូចជាកំពូលភ្នំឋិតនៅមាំដូចសសរគោល មិនញាប់ញ័រ

មិនប្រែប្រួល មិនបៀតបៀននូវគ្នា និងគ្នា មិនអាចធ្វើគ្នា និងគ្នាឱ្យបានសុខ ឬឱ្យបានទុក្ខ ឬទាំងសុខទាំងទុក្ខទេ។

**៥-គ្រូឈ្មោះនិគន្ថនាដបុត្ត** ពោលថា និគ្រន្ថបាន សង្រួមចែកជាបួនចំណែកដូចតទៅនេះ

+ឃាត់ហាមទឹកទាំងពួង ក្នុងអដ្ឋកថាប្រាប់ថា ឃាត់ហាមទឹកត្រជាក់គ្រប់មុខដោយសម្គាល់ថា ក្នុងទឹកត្រជាក់មានសត្វមិនគួរប្រើប្រាស់ឡើយ។

+ប្រកបដោយទឹកទាំងពួង គឺប្រកបដោយការរាំងផ្លូវបាបទាំងពួង ក្នុងដីកាថា ប្រកបដោយការសង្រួមគ្រប់ប្រការ។

+កម្ចាត់ដោយទឹកបាបទាំងពួង ក្នុងអដ្ឋកថាគឺ កម្ចាត់បាបដោយប្រការរាំងផ្លូវបាបទាំងពួង។

+ព្រោះព្រំដោយទឹកទាំងពួង ក្នុងអដ្ឋកថា ព្រោះព្រំដោយការរាំងផ្លូវបាបទាំងពួង (តាមន័យនៃអដ្ឋកថា និងដីកាត្រង់ពាក្យថា ទឹកជាឈ្មោះនៃការរាំងផ្លូវបាប)។ ការបានសង្រួមនូវចំណែក ៤ យ៉ាងនេះ និគ្រន្ថនេះគេហៅថា អ្នកមានខ្លួនដល់នូវទីបំផុតផង មានខ្លួនសង្រួមហើយផង មានខ្លួននៅដោយល្អផង។

**៦-គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្ត** ពោលថា បើមានគេសួរថា លោកខាងមុខមានដែរឬ បើ

ការយល់ឃើញរបស់យើងថា លោកខាងមុខ
មាន យើងគប្បីដោះស្រាយនូវហេតុនោះ ថា
លោកខាងមុខមាន ឯការយល់ឃើញនោះ
យ៉ាងនេះក៏មិនមែន យ៉ាងនោះក៏មិនមែន ថា
មិនមែនក៏ទេ ថាមិនមែនទេ ក៏មិនមែនដែរ។

សេចក្តីយល់ឃើញថា លោកខាងមុខមិន
មាន មានខ្លះមិនមានខ្លះ មានក៏មិនមែន
មិនមានក៏មិនមែន។ ពួកសត្វជា ឧបបាតិកៈ
មាន មិនមាន មានខ្លះមិនមែនខ្លះ មានក៏មិន
មែន មិនមានក៏មិនមែន។ ក្នុងអដ្ឋកថា
បញ្ជាក់ថា ៖

+ពាក្យថា យ៉ាងនេះក៏មិនមែន ជាពាក្យឃាត់អាការៈសួរណាៗ ដែលមិនមានទីកំណត់។

+ពាក្យថា យ៉ាងនោះក៏មិនមែន ជាពាក្យឃាត់សស្សតវាទ គឺពាក្យថា លោកទៀង។

+ពាក្យថា យ៉ាងដទៃក៏មែន ជាពាក្យឃាត់ឯកច្ចសស្សត ឯកច្ចអសស្សតវាទ គឺពាក្យលោកទៀងខ្លះ មិនទៀងខ្លះ។

+ពាក្យថា មិនមែនក៏ទេ ជាពាក្យឃាត់ឧច្ឆេទវាទ គឺពាក្យថា សត្វស្លាប់ទៅសូន្យមិនកើតទៀត។

+ពាក្យថា មិនមានក៏ទេ ក៏មិនមែនដែរ ជាពាក្យឃាត់តក្កវាទ (ការត្រិះរិះ) គឺពាក្យថា សត្វស្លាប់ទៅមិនមែនជាមាន មិនមែនជាគ្មាន។

-ដំណើរនៃទិដ្ឋិនេះ បើពោលបំព្រួញមក មាន **សស្សតទិដ្ឋិ** សេចក្តីយល់ឃើញថាទៀង

-**ឧច្ឆេទទិដ្ឋិ** សេចក្តីយល់ឃើញថាដាច់សូន្យ

-**អហេតុទិដ្ឋិ** សេចក្តីយល់ឃើញថា សត្វឥតមានហេតុ១

-**អកិរិយទិដ្ឋិ** សេចក្តីយល់ឃើញថាធ្វើអំពើអាក្រក់ឥតបាប១

៣-**នត្ថិកទិដ្ឋិ** សេចក្តីយល់ឃើញថាធ្វើអំពើអ្វីៗ ឥតផល១។ ទិដ្ឋិទាំងនេះបើដល់ថ្នាក់ទៀងលែងប្រែប្រួល នឹងប្រព្រឹត្តិទៅជា **និយតមិច្ឆាទិដ្ឋិ** ឈ្មោះថាកិលេសន្តរាយិកៈ ធ្វើឱ្យអន្តរាយ ទាំងផ្លូវសួគ៌ ទាំងផ្លូវនិព្វាន។

## ៤-អវិជ្ជោឃៈ អន្លង់ គឺ អវិជ្ជា

ពាក្យថា **អវិជ្ជា** ឬ **អញ្ញាណៈ** ប្រែថា ការមិនដឹងច្បាស់ សេចក្តីល្ងង់ **មោហៈ** ឬ **មោឃោ** សត្វលោកត្រូវអវិជ្ជារួបរឹត ភ័ន្តច្រឡំយល់ខុសថាជាត្រូវ។ **អញ្ញាណៈ** ឬ **អវិជ្ជា** នេះ

ជាឈ្មោះនៃការមិនចេះដឹង ឬកិលេសធម៌ជាគ្រឿងបិទបាំងប្រាជ្ញា។

## អវិជ្ជាមាន ៨ យ៉ាង

១_ទុក្ខេ អញ្ញាណៈ មិនដឹងក្នុងកងទុក្ខ

២_ទុក្ខសមុទយេ អញ្ញាណៈ មិនដឹងក្នុងហេតុនៃទុក្ខ។

៣_ទុក្ខនិរោធេ អញ្ញាណៈ មិនដឹងក្នុងការរលត់ទុក្ខ។

៤_ទុក្ខនិរោធគាមិនិយា អញ្ញាណៈ មិនដឹងក្នុងបដិបទាដែលដល់នូវការរលត់ទុក្ខ។

៥_បុព្វន្តេ អញ្ញាណៈ មិនដឹងកាលអតីត។

**៦_អបរន្តេ អញ្ញាណៈ** មិនដឹងក្នុងកាលអនាគត។

**៧_បុព្វន្តាបរន្តេ អញ្ញាណៈ** មិនដឹងទាំងកាលអតីត ទាំងអនាគត។

**៨_បដិច្ចសមុប្បាទេ អញ្ញាណៈ** មិនដឹងក្នុងបដិច្ចសមុប្បាទ។

**១_ពាក្យថា** "មិនដឹងក្នុងកងទុក្ខ" បានដល់ការមិនដឹងច្បាស់នូវទុក្ខសច្ចៈ គឺសេចក្តីទុក្ខទាំង ១២ កង គឺៈ

**-ជាតិទុក្ខ** សេចក្តីទុក្ខព្រោះមានជាតិជាបច្ច័យ។

**-ជរាទុក្ខ** ទុក្ខព្រោះជរាជាបច្ច័យ។

**-ព្យាធិទុក្ខ** ទុក្ខព្រោះមានរោគបៀតបៀនយាយីជាបច្ច័យ។

**-មរណៈទុក្ខ** ទុក្ខព្រោះមានសេចក្តីស្លាប់ជាបច្ច័យ។

**-សោកទុក្ខ** ទុក្ខបណ្តាលឱ្យស្តាយស្រណោះអាឡោះអាល័យ ចំពោះសត្វ និងសង្ខារជាទីស្រលាញ់ពេញចិត្តដែលព្រាត់ប្រាស់ទៅ។

**-បរិទេវទុក្ខ** ទុក្ខបណ្ដាលឱ្យត្អូញត្អែររៀបរាប់ពីការកំសត់ កម្រផ្សេងៗ និងសង្ខារដែលព្រាត់ប្រាស់ទៅ។

**-ទុក្ខទុក្ខ** ទុក្ខលំបាកតែចំណែកផ្លូវកាយដោយការនឿយហត់ផ្សេងៗ។

**-ទោមនស្សទុក្ខ** ទុក្ខព្រោះសេចក្ដីអាក់អន់ចំពោះអារម្មណ៍ដែលឈ្នើសចិត្ត។

**-ឧបាយាសទុក្ខ** ទុក្ខបណ្ដាលឱ្យអាក់អួលទង្គឹះ ដោយអាការៈ តានតឹងក្នុងចិត្ត ព្រោះនឹកឃើញដល់សត្វ និងសង្ខារជាទីស្រលាញ់ពេញចិត្ត ដែលព្រាត់ប្រាស់ទៅយូរហើយ។

**-អប្បិយេហិ សម្បយោគទុក្ខ** ទុក្ខព្រោះជួប
ប្រសព្វសត្វនិងសង្ខារដែលមិនត្រូវចិត្ត ។

**-បិយេហិ វិប្បយោគទុក្ខ** ទុក្ខព្រោះព្រាត់
ប្រាសនិរាសចាកសត្វ និងសង្ខារដែលខ្លួន
ពេញចិត្ត។

**-យម្បិច្ឆំ នលភតិតម្បិទុក្ខ** ទុក្ខកើតមកពី
ប្រាថ្នារបស់មិនបានដូចបំណង ចង់បានរបស់
ណា មិនបានរបស់នោះ។

**សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធាទុក្ខា** ទុក្ខទាំង
អស់ ប្រមូលមកមានតែឧបាទានក្ខន្ធ ទាំង៥
ជាមេទុក្ខ។

# មានទុក្ខដទៃ ៧ យ៉ាងទៀតគឺ

១-**ទុក្ខទុក្ខ** ទុក្ខវេទនាដែលប្រព្រឹត្តិទៅក្នុងកាយ និងចិត្តហើយ ព្រោះកាយសម្រាប់ទទួលនូវទុក្ខ ថែមទាំងទុក្ខដទៃមួយមកត្រួតទៀតជាពីរឈ្មោះ ថាទុក្ខទុក្ខ។

២-**វិបរិណាមទុក្ខ** វេទនាដែលសោយនូវសេចក្ដីសុខ កើតសេចក្ដីទុក្ខឡើងវិញ នាំឱ្យប្រាសចាកសេចក្ដីសុខ ឈ្មោះថា **វិបរិណាមទុក្ខ**។

៣-**សង្ខារទុក្ខ** សង្ខារដែលប្រព្រឹត្តិទៅក្នុងភព ៣ ប្រកបដោយឧបេក្ខាវេទនាគឺ សេចក្ដី

កើត និងវិនាសចូលទៅបៀតបៀន ឈ្មោះសង្ខារទុក្ខ។

៤_**បដិច្ឆន្នទុក្ខ** អាពាធដែលប្រព្រឹត្តិទៅក្នុងកាយនិងចិត្ត មានឈឺត្រចៀកនិងធ្មេញជាដើម លុះតែមានគេសួរទើបដឹង កើតតែខាងក្នុងមិនប្រាកដដល់ភ្នែកអ្នកទាំងពួងឡើយ។

**៥-អបដិច្ឆន្នទុក្ខ** ជំងឺដែលមានសមុដ្ឋានធ្វើនូវអាការៈ ៣២ មានសក់ស្កូវជាដើម មិនចាំបាច់អ្នកណាសួរ ក៏គួរដឹងបានដូច្នេះ ឈ្មោះថា **អបដិច្ឆន្នទុក្ខ**។

**៦_បរិយាយទុក្ខ** ទុក្ខទាំអស់លើកលែងតែទុក្ខទុក្ខ១ចេញទេ មានជាតិទុក្ខជាដើម ដែលមានក្នុងសច្ចៈ ឈ្មោះថា **បរិយាយទុក្ខ**។

**៧_និប្បរិយាយទុក្ខ** ចំណែកទុក្ខទុក្ខឈ្មោះថា **និប្បរិយាយទុក្ខ**។

**២_ពាក្យថា** "មិនដឹងក្នុងហេតុនៃទុក្ខ" បានដល់ការមិនដឹងក្នុងទុក្ខសមុទយសច្ចៈ គឺ **តណ្ហា៣**, កាមតណ្ហា១, ភវតណ្ហា១, វិភវ_តណ្ហា១។

**៣_ពាក្យថា** "មិនដឹងការរំលត់ទុក្ខ" បានដល់ការមិនដឹងច្បាស់ក្នុងនិរោធសច្ចៈ។

**៤-ពាក្យថា** "មិនដឹងក្នុងបដិបទាដែលដល់នូវការរលត់ទុក្ខ" បានដល់ការមិនដឹងច្បាស់ក្នុងមគ្គសច្ចៈ។

**៥-ពាក្យថា** "មិនដឹងក្នុងកាលអតីត" គឺការមិនដឹងក្នុងខន្ធជាចំណែកខាងដើម។

**៦-ពាក្យថា** "មិនដឹងក្នុងកាលអនាគត" បានដល់ការមិនដឹង ក្នុងខន្ធជាចំណែកខាងចុង។

**៧-ពាក្យថា** "ការមិនដឹងក្នុងកាលទាំងអតីត និងអនាគត" បានដល់ការមិនដឹងក្នុងខន្ធជាចំណែកខាងដើម នឹងខាងចុង។

**៨-ពាក្យថា** "មិនដឹងក្នុងបដិច្ចសមុប្បាទ" បានដល់ការមិនដឹងក្នុងធម៌ជាបច្ច័យ ដែលកើតឡើងព្រោះអាស្រ័យគ្នា ដូចកូនច្រវ៉ាក់ថ្កក់ជាប់គ្នាពីមួយទៅមួយគឺ អវិជ្ជា១, សង្ខារ១, វិញ្ញាណ១, នាមរូប១, សឡាយតនៈ១, ផស្ស១, វេទនា១, តណ្ហា១, ឧបាទាន១, ភព១, ជាតិ១, ជរាមរណ១ ធម៌ដែលកើតឡើងតៗគ្នានេះ ហៅថា បដិច្ចសមុប្បាទ។

ការសម្ដែងអំពីឱឃៈ ៤ ជាគ្រឿងទាញសត្វឱ្យជន់លិចក្នុងសមុទ្រទុក្ខគឺ សង្សារវដ្ដៈ ចប់តែប៉ុណ្ណេះ ។

# អំពីការឆ្លងអន្លង់

**ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកហើយយ៉ាង នេះថា ។

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្ត វណ្ណា កេវលកប្បំ ជេតវនំ ឧភាសេត្វា យេន ភគវា តេនុបសង្កមិ**

**ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ។** លំដាប់នោះឯង ទេវតាអង្គ១ កាលដែលវេលារាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អមញ្ញាំងវត្តជេតពន ជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណាក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះមានព្រះភាគ ហើយឈរនៅក្នុង ទីដ៏សមគួរ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** លុះទេវតានោះ ឈរ

ក្នុងទីដ៏សមគួរហើយ ទើបពោលគាថាសួរព្រះមានព្រះភាគថា

**កតិ ឆិន្ទេ កតិ ជហេ កតិ វុត្តរិ**

**ភាវយេ កតិ សង្គាតិគោ ភិក្ខុ**

**ឱឃតិណ្ណោតិ វុច្ចតីតិ** ជនត្រូវកាត់បង់ធម៌ប៉ុន្មាន ត្រូវលះបង់ធម៌ប៉ុន្មាន ត្រូវអប់រំធម៌ប៉ុន្មានតទៅ ភិក្ខុកន្លងបង់នូវធម៌ជាគ្រឿងជំពាក់ប៉ុន្មាន ទើបហៅថា អ្នកឆ្លងឱឃៈបាន។

**បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច វុត្តរិ**

**ភាវយេ បញ្ច សង្គាតិគោ ភិក្ខុ**

**ឱយតិណ្ណោតិ វុច្ចតីតិ** ព្រះមានព្រះភាគ ត្រាស់តបថា ជនត្រូវកាត់សំយោជនៈជាចំណែកខាងក្រោម ៥ គឺ:

១_**សក្កាយទិដ្ឋិ** សេចក្តីឃើញថាហេតុប្រកាន់ខ្លួន។

២_**វិចិកិច្ឆា** សេចក្តីស្ទាក់ស្ទើរជាហេតុមិនប្រាកដចិត្ត ក្នុងបដិបទា គ្រឿងដំណើររបស់ខ្លួន។

៣_**សីលព្វតួបរាមាស** សេចក្តីជឿប្រកាន់ស័ក្តិសិទ្ធិដោយចូលចិត្តថា អាចមានបានដោយសីល ឬវត្តយ៉ាងនោះ។

**៤_កាមរាគៈ** សេចក្តីតម្រេកដោយអំណាចកិលេសកាម ហៅតែត្រឹមថា រាគៈក៏មាន

**៥_បដិឃៈ** សេចក្តីខ្ទាំងខ្ទប់នៃចិត្ត បានដល់សេចក្តីងងឹតងងុលដោយអំណាចទោសៈ ហៅ ទោសៈ ត្រង់តែម្តងក៏មាន ៥នេះជាសំយោជនៈខាងក្រោម គឺ យ៉ាងជ្រោកជ្រាក ហៅថា **ឱរម្ភាគិយៈ** ។ ត្រូវលះបង់សំយោជនៈជាចំណែកខាងលើ ៥ គឺៈ

**៦_រូបរាគៈ** សេចក្តីជាប់ចិត្តនៅក្នុងរូបធម៌ ដូចយ៉ាងគាប់ចិត្តនៅក្នុងបុគ្គលពួកខ្លះ ឬ

ក្នុងវត្ថុពួកខ្លះ ឬស្ងួម្បីក្នុងវត្ថុដែលជាអា-
រម្មណ៍នៃរូបឈាន

៧-**អរូបរាគៈ** សេចក្ដីជាប់ចិត្តនៅក្នុងអរូប
ធម៌ ដូចសេចក្ដីគាប់ចិត្តក្នុងសុខវេទនា

៨-**មានៈ** សេចក្ដីសំគាល់ខ្លួនថាជានោះជា
នេះ

៩-**ឧទ្ធច្ចៈ** សេចក្ដីអណ្ដែតអណ្ដូងនៃចិត្ត ដូច
យ៉ាងនឹកអ្វីក៏នឹករវើរវាយទៅលើសជាង
ហេតុ

១០-**អវិជ្ជា** សេចក្ដីវង្វេងដែលជាហេតុមិន
ឱ្យដឹងពិត។ ៥ នេះជាសំយោជនៈខាង

លើគី យ៉ាងល្អិត។ ត្រូវអប់រំនូវឥន្ទ្រីយទាំង ៥ គឺ:

១-សទ្ធិន្ទ្រិយ ឥន្ទ្រីយ គឺសទ្ធា (ជឿជាក់)

២-វិរិយិន្ទ្រិយ ឥន្ទ្រីយ គឺវិរិយ:(ព្យាយាមជាធំ)

៣-សតិន្ទ្រិយ ឥន្ទ្រីយ គឺសតិជាធំ

៤-សមាធិន្ទ្រិយ ឥន្ទ្រីយ គឺសមាធិជាធំ

៥-បញ្ញិន្ទ្រិយ ឥន្ទ្រីយ គឺបញ្ញា។ តទៅភិក្ខុកន្លងបង់នូវសង្គ:គឺធម៌ជាគ្រឿងជំពាក់[៤] ទាំង ៥ យ៉ាងទើបហៅថា អ្នកឆ្លងអន្លង់បាន។

---

(៤) សំដៅយក រាគ: ទោស: មោហ: មាន: ទិដ្ឋិ។

ព្រះសម្ពុទ្ធទ្រង់ចង្អុលបង្ហាញនូវយានដ៏ សំខាន់ ៤ យ៉ាងសម្រាប់ឆ្លងឱ្យផុតអំពីអន្លង់ទាំង ៤ ទៀត គឺៈ

**១-សទ្ធាយ តរតិ ឱឃំ** សត្វឆ្លងអន្លង់ទៅបានដោយសារសទ្ធា ។

**២-អប្បមាទេន អណ្ណវំ** សត្វឆ្លងសមុទ្រទុក្ខទៅបានដោយសារសេចក្ដីមិនធ្វេសប្រហែស ។

**៣-វិរិយេន ទុក្ខមច្ចេតិ** សត្វឆ្លងសេចក្ដីទុក្ខទៅបានដោយសារសេចក្ដីព្យាយាម។

## ៤-បញ្ញាយ បរិសុជ្ឈតិ សត្វឆ្លងសេចក្តីមិនបរិសុទ្ធអោយបរិសុទ្ធបានដោយសារបញ្ញា។

## សេចក្តីអធិប្បាយ

១~តាមទំនៀមមកថា អ្នកស្រុក អ្នកប្រទេសដែលគេតែងតែឆ្លងស្ទឹង ទន្លេ ឬសមុទ្រជាដើមនោះ សុទ្ធតែគេត្រូវស្វែងរកនាវាតូចធំទើបនឹងអាចឆ្លងស្ទឹង ទន្លេឬសមុទ្រជាដើមនោះបាន បើរៀវតែរបស់ប៉ុណ្ណោះហើយ ក៏មិនអាចនឹងឆ្លងបានឡើយ ឯក្នុងទីនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា :

**សទ្ធាយ តរតិ ឱឃំ** "សត្វឆ្លងអន្លង់បានដោយសារសទ្ធា" ដូច្នេះវិញ។ ក៏សទ្ធាក្នុងបទនេះសំដៅយកសទ្ធា ២ ប្រការគឺ បសាទលក្ខណៈសទ្ធា សទ្ធាដែលមានសេចក្តីជ្រះថ្លាជាលក្ខណៈ១, បក្ខន្ទលក្ខណៈសទ្ធា សទ្ធាដែលមានកិរិយាស្ទុះទៅជាលក្ខណៈ១, សទ្ធាទាំង ២ ប្រការនេះហើយ ដែលសម្រាប់ឆ្លងជំនន់ គឺសេចក្តីយល់ឃើញខុសនោះឱ្យបានជាត្រឹមត្រូវឡើងវិញ។ ហេតុដូច្នេះបានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សម្តែងថា **សទ្ធាយ តរតិឱឃំ** "សត្វឆ្លងអន្លង់បានដោយសារសទ្ធា"។

(សេចក្តីបំព្រួញថា សត្វឆ្លង **ទិដ្ឋោឃៈ** "អន្លង់ គឺទិដ្ឋិ" បានដោយសារសោតាបត្តិមគ្គ)

**២**-សត្វឆ្លងនូវសមុទ្រសាគរ គឺសង្សារវដ្ត បានដោយសារសេចក្តីប្រុងប្រយ័ត្ន សមុទ្រគឺសង្សារវដ្តដែលមានជំនន់ គឺភពជាវត្ថុនេះ សត្វមិនអាចនឹងឆ្លងបានដោយវត្ថុអ្វីដទៃឡើយ លុះតែសត្វណាដែលបានសម្រេចជាសោតាបន្នបុគ្គល ដែលប្រកបព្រមដោយសេចក្តីមិនប្រមាទ ពោលគឺញ៉ាំងធម៌ជាកុសលទាំងឡាយឱ្យចម្រើនឡើងរឿយៗ ហើយញ៉ាំងមគ្គទី២ គឺសកទាគាមិមគ្គឱ្យកើតឡើងទើបនឹងឆ្លងបាន ព្រោះហេតុដូច្នេះ

បានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា **អប្បមាទេន អណ្ណវំ** "សត្វឆ្លងសង្សារវដ្តបាន ដោយសារសេចក្តីមិនប្រមាទ"។

(សេចក្តីបំព្រួញថា សត្វឆ្លង **ភវោឃៈ** "អន្លង់ គឺភព" បានដោយសារសកទាគាមិ-មគ្គ)។

**៣**.សត្វឆ្លងនូវសេចក្តីទុក្ខលំបាកបាន ដោយសារសេចក្តីព្យាយាមប្រឹងប្រែង ដែលជាឈ្មោះវីរិយចេតសិក ឯវីរិយនេះ ជាអញ្ញ-សមានាចេតសិក ប្រព្រឹត្តិទៅបានទាំងក្នុងចំណែកល្អ និងចំណែកអាក្រក់ ក៏ឯក្នុងពុទ្ធភា

សិតនេះ សំដៅយកសេចក្តីព្យាយាមក្នុងចំណែកល្អតែម្យ៉ាង ហេតុដូច្នេះបានជាព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា **វីរិយេន ទុក្ខមច្ចេតិ** "សត្វឆ្លងនូវសេចក្តីទុក្ខលំបាកបានដោយសេចក្តីព្យាយាម"។

(សេចក្តីបំព្រួញថា សត្វឆ្លង **កាមោឃៈ** "អន្លង់ គឺកាម" បានដោយសារអនាគាមិមគ្គ)

**៤**~សត្វបរិសុទ្ធបាន ដោយសារប្រាជ្ញា ប្រាជ្ញាក្នុងទីនេះ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ព្រះអនាគាមិបុគ្គល បានញាំង

ប្រាជ្ញាដ៏សម្បយុត្តដោយមគ្គជាគម្រប់ ៤[៥] ឱ្យ បរិសុទ្ធដោយចំណែកមួយ ដោយញាណដ៏បរិសុទ្ធដែលប្រាស់ចាកភក់ គឺកាម ហើយបានលះបង់នូវមន្ទិលដ៏ល្អិតពោលគឺ អវិជ្ជាដែលព្រះអនាគាមិ មិនទាន់លះបង់បាននោះ ព្រោះហេតុដូច្នេះ បានជាព្រះអង្គទ្រង់ប្រកាសនូវអរហត្តមគ្គផង នូវអរហត្តផលផង ដែលជាគ្រឿងឆ្លងចាកអវិជ្ជាដោយបទថា **បញ្ញាយ បរិសុជ្ឈតិ** "សត្វបរិសុទ្ធបានដោយសារប្រាជ្ញា"។

---

[៥] មគ្គជាគម្រប់៤គឺ សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ។

(សេចក្តីបំព្រួញថា ឆ្លងនូវ អវិជ្ជោឃៈ "អន្លង់ គឺអវិជ្ជា" បានដោយសារអរហត្តមគ្គ)។

ចប់ការឆ្លងអន្លង់ ៤ តែប៉ុណ្ណេះ។

# ទេវទូតសូត្រ

**ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ។ **ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ** កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ។ **ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំង

នោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគ ថា ព្រះករុណាព្រះអង្គ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មានផ្ទះពីរ ប្រកបដោយទ្វារ ក្នុងផ្ទះនោះ មានបុរសភ្នែកភ្លឺម្នាក់ ឈរចំកណ្តាល គប្បីមើលឃើញពួកមនុស្ស ដែលកំពុងដើរចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី កំពុងសញ្ចរទៅមកក្តី កំពុងត្រាច់ទៅមកក្តី សេចក្តីមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចតថាគត មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងលើសចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញពួកសត្វលោក

ដែលច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសប្បុរល្អ មានសប្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនត្រិះដៀល ព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ចំណែកសត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកប

ដោយ មនោសុចរិត ជាអ្នកមិនត្រិះដៀលព្រះ អរិយ បុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់ នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះបែក ធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុង មនុស្សលោក អើហ្ន៎ សត្វទាំងនេះប្រកប ដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកត្រិះដៀល ព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រ កាន់នូវអំពើ ជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុង កំណើតប្រេតវិស័យ ចំណែកសត្វទាំង ឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកប

ដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកត្រិះដៀល ព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ចំណែកពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកត្រិះដៀលព្រះអរិយបុគ្គលទាំងឡាយ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់បុរសនោះត្រង់ដើមដៃផ្សេងៗ នាំយកទៅថ្វាយព្រះយមរាជ[៦] រួចក្រាបទូលថាបពិត្រព្រះឧបបត្តិទេព បុរសនេះ ជាអ្នកមិនគោរពមាតាបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនកោតក្រែងក្នុងត្រកូលរៀម

---

[៦] ស្តេចនោះ គឺជាស្តេចវេមានិកប្រេត ព្រោះវេមា-និកប្រេតនេះ ជួនកាលសោយទិព្វសម្បត្តិ គឺមានដើមកប្បព្រឹក្សជាទិព្វ ឧទ្យានជាទិព្វ ស្រីរបាំជាទិព្វ ក្នុងទិព្វវិមាន ជួនកាលក្លាយទៅជាព្រះយមរាជ សោយកម្មវិបាក។ អដ្ឋកថា ។

ច្បងទេ សូមទ្រង់ដាក់អាជ្ញាដល់បុរសនេះ ចុះ។

ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជ សាកសួរដេញដោល សួរឈ្លេចឈ្លី នូវ

**ទេវទូតទី១** នឹងបុរសនោះថា នែបុរស អ្នកឯងមិនបានឃើញទេវទូតទី១ ដែលកើតប្រាកដ ក្នុងមនុស្សលោក ទេឬ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា ម្នាលបុរស អ្នកឯងមិនបាន ឃើញកូនខ្ចីកំពុងដេកផ្ងារ ដេក

ត្រាំទឹកមូត្រ និងលាមករបស់ខ្លួន ក្នុងមនុស្សលោកទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា អាត្មាអញឯង មានជាតិជាធម្មតា មិនកន្លងនូវជាតិទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹកគិតឃើញដូច្នោះ) បានឡើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះ

អង្គជាមនុស្សប្រមាទ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជមានព្រះឱង្ការ ពន្យល់បុរសនោះ យ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯង មិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួកមិត្ត អាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឱ្យទេ មិនមែន

ពួកសមណៈព្រាហ្មណ៍ធ្វើឱ្យទេ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹង ត្រូវទទួលវិបាក នៃបាបកម្មនោះវិញ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី១ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លី នូវ

**ទេវទូតទី២** ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញ ទេវទូតទី២ ដែលកើតប្រាកដក្នុងមនុស្ស លោកទេឬ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តា

ប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះយ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងមិនបានឃើញស្រីឬបុរស ដែលមានអាយុ ៨០ ឆ្នាំ ៩០ ឆ្នាំឬ ១០០ ឆ្នាំ ដែលចាស់គ្រាំគ្រាអំពីកំណើតមានឆ្អឹងជំនីរ កោងដូចជាបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ដើរទៅញ័ររន្ធត់ ក្តៅអន្ទះសា មានវ័យជ្រុលហួសហើយ មានធ្មេញបាក់ មានសក់ស្កូវ មានក្បាលឆក មានក្បាលទំពែក មានស្បែកជ្រួញជ្រាវ មានខ្លួនសៅហ្មង ដោយប្រជ្រុយ ក្នុងមនុស្សលោកទេឬ។ បុរសនោះក្រាបទូលយ៉ាងនេះ

ថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបាន ឃើញ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា អាត្មាអញឯងមានសេចក្តីគ្រាំគ្រាជាធម្មតា មិនកន្លងនូវសេចក្តីគ្រាំគ្រាទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹកគិតឃើញ)ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្ស

ប្រមាទ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជក៏ត្រាស់ពន្យល់បុរសយ៉ាង នេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាល នឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្ម របស់អ្នកនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួក មិត្តអាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសា លោហិតធ្វើឱ្យទេ មិនមែនពួកសមណៈ ព្រាហ្មណ៍ធ្វើឱ្យទេ មិន

មែនទេវតាទាំង ឡាយធ្វើឱ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួល វិបាក នៃបាបកម្ម នោះវិញ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាក សួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ២ នឹងបុរសនោះរួចហើយ ទើបសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវ

**ទេវទូតទី៣** ទៀតថា ម្នាលបុរស អ្នក ឯងមិនបានឃើញ ទេវទូតទី៣ ដែលកើត ប្រាកដក្នុងមនុស្ស លោកទេឬ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តា ប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ។ ម្នាល

ភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរស
នោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិន
បានឃើញស្រីឬបុរស ដែលមានជម្ងឺ ដល់នូវ
សេចក្ដីលំបាក ឈឺធ្ងន់ កំពុងដេកត្រាំក្នុងទឹក
មូត្រនិងលាមករបស់ខ្លួន លុះតែមានពួកជន
ដទៃគ្រាហ៍ទើបក្រោយរួច មានពួកជនដទៃ
គ្រាហ៍ទើបចូលមកបាន ក្នុងមនុស្សលោក
ទេឬ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា
សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបាន
ឃើញ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ
សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស
កាលអ្នកឯងនោះ ដឹងក្ដីឡើងរហូតដល់ចាស់

តើមានគំនិតថា អាត្មាអញឯង មានជម្ងឺជាធម្មតា មិនកន្លងនូវ ជម្ងឺទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹកគិតឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯង មិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង

មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាល នឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្ម របស់អ្នកនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែន បិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួក មិត្តអាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឱ្យទេ មិនមែនពួកសមណៈព្រាហ្មណ៍ធ្វើឱ្យទេ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ បាបកម្មនុ៎ះ គឺអ្នកឯង ធ្វើខ្លួនឯង អ្នកឯង នឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី៣ នឹងបុរសនោះរួចហើយ ទើបសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវ

**ទេវទូតទី៤** ទៀតថា នែបុរស អ្នកឯងមិនបានឃើញ ទេវទូតទី៤ ដែលកើតប្រាកដ ក្នុងមនុស្ស លោកទេឬ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងមិនបានឃើញនូវ ព្រះរាជាទាំងឡាយ

កាលចាប់ចោរ ដែលព្រឹត្តិអាក្រក់បាន ហើយ
ត្រាស់បង្គាប់ឱ្យធ្វើ កម្មករណ៍ផ្សេងៗ គឺឱ្យ
វាយដោយរំពាត់ខ្លះ ឱ្យវាយដោយផ្តៅខ្លះ ឱ្យ
វាយដោយដំបងខ្លីខ្លះ ឱ្យកាត់ដៃខ្លះ ឱ្យកាត់
ជើងខ្លះ ឱ្យកាត់ទាំងដៃ ទាំងជើងខ្លះ ឱ្យកាត់
ស្លឹកត្រចៀកខ្លះ ឱ្យកាត់ច្រមុះខ្លះ ឱ្យកាត់ទាំង
ស្លឹកត្រចៀកទាំងច្រមុះខ្លះ ឱ្យធ្វើពិលង្គថា
លិកកម្ម គឺអំពើដែលគេធ្វើ ឱ្យដូចជាឆ្នាំង
ដាក់ទឹកជ្រក់ខ្លះ ឱ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំ
ពើដែលគេធ្វើមាត់ ឱ្យដូចជាមាត់រាហុខ្លះ ឱ្យ
ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួន
មនុស្សឱ្យដូចជាផ្កាភ្លើងខ្លះ ឱ្យធ្វើនូវហត្ថប្ប-

ជោតិកកម្ម គឺអំពើដែលគេ ដុតដៃខ្លះ ឱ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែល គេធ្វើឱ្យដូចពន្លាត់ស្បែកពពែខ្លះ ឱ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឱ្យដូចជា ស្លៀកសំពត់សំបកឈើខ្លះ ឱ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឱ្យដូចជាជើងសត្វទ្រាយខ្លះ ឱ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ឱ្យធ្វើនូវកហា-នណកកម្ម គឺអំពើដែលគេធ្វើឱ្យ ខូចសរីរៈប្រមាណប៉ុនកហាបណៈមួយៗ ខ្លះ ឱ្យធ្វើខារាបតច្ឆិកកម្ម គឺអំពើដែលគេយក ទឹកផ្សាស្រោចខ្លះ ឱ្យធ្វើនូវបលិឃបវត្តិកកម្ម គឺអំពើដែលធ្វើ

ឱ្យដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ឱ្យធ្វើនូវបលាលបីថកកម្ម គឺអំពើដែលគេធ្វើឱ្យដូចជាកណ្តាប់ចំបើងខ្លះ ឱ្យស្រោចប្រេងដែលក្តៅខ្លះ ឱ្យឆ្កែខាំខ្លះ ឱ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឱ្យកាត់ក្បាលដោយដាវខ្លះ ដូច្នេះដែរឬទេ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះ មេត្តាប្រោសខ្ញុំព្រះអង្គបានឃើញ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា បានឮថា អ្នកណាធ្វើនូវបាបកម្មទាំងឡាយ អ្នកនោះ

គេនឹងធ្វើកម្មករណ៍ផ្សេងៗ យ៉ាងនេះវិញ ក្នុងបច្ចុប្បន្ននេះឯង នឹងបាច់និយាយថ្វី ក្នុងបរលោក បើដូច្នោះ គួរតែអាត្មា អញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹកគិតឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯង មិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស

បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួក មិត្រអាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឱ្យទេ មិនមែនពួកសមណៈ ព្រាហ្មណ៍ធ្វើឱ្យទេ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៤ នឹងបុរសនោះរួចហើយ ទើបសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវ

**ទេវទូតទី៥** ទៀតថា នែបុរស អ្នកឯងមិនបានឃើញទេវទូតទី៥ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញស្រីឬបុរស ដែលស្លាប់អស់មួយថ្ងៃ

ឬស្លាប់អស់ពីរថ្ងៃ ឬក៏ស្លាប់អស់បីថ្ងៃ កំពុងហើមប៉ោង មានសម្បុរខៀវ ដោយច្រើនមានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ទេឬ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នៃបុរស កាលអ្នកឯងនោះ ដឹងក្តីឡើង រហូតដល់ចាស់ តើមានគំនិតថា អាត្មាអញឯង មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ បើដូច្នេះ គួរតែអាត្មាអញ ធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬ។

បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹកគិតឃើញ)ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះ ថានែបុរស ព្រោះតែសេចក្ដីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមានសេចក្ដីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឱ្យទេ មិនមែនបិតាធ្វើឱ្យទេ មិនមែនបងប្អូនប្រុសធ្វើ

ឱ្យទេ មិនមែនបងប្អូនស្រីធ្វើឱ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឱ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឱ្យទេ មិនមែនពួកសមណៈព្រាហ្មណ៍ធ្វើឱ្យទេ មិនមែនទេវតាទាំងឡាយធ្វើឱ្យទេ បាបកម្មនុ៎ះ គឺអ្នកឯង ធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី៥ នឹងបុរសនោះរួចហើយ ក៏ទ្រង់នៅស្ងៀម[៧]។

---

[៧] សត្វណាដែលព្រះយមរាជគួរសួរដេញដោលអំពីទេវទូតទាំង ៥នោះ សត្វណាដែលមិនគួរសួរដេញដោល

។ សត្វដែលធ្វើបាបកម្មច្រើន ត្រូវទៅកើតក្នុងនរកតែម្តង ព្រះយមរាជមិនចាប់សួរទេ ចំណែកសត្វដែលធ្វើបាបកម្មតិច ត្រូវយមរាជសួរដេញដោលអំពីទេវទូត រឿងនេះដូចគ្នានឹងរាជបុរសដែលចាប់ចោរបាន ព្រមទាំងព្រទ្យជាព័សតាង ហើយយកមកដាក់ទោស តែម្តងមិនបាចជំនុំជំរះ ចំណែកចោរណាដែលចាប់បានល្មមនឹងសាកសួរ ក៏យកទៅសាលា វិនិច្ឆ័យឱ្យសាកសួរមើលសិន។ ពិតមែន សត្វដែលធ្វើបាបកម្មតិច ចួនកាលនឹងឃើញតាមធម្មតាខ្លួនឯង ព្រះយមរាជតែសួរនូវទេវទូតទាំង៥។ ក្នុងទេវទូតទាំង ៥ នោះ សត្វខ្លះនឹកឃើញត្រង់ទេវទូតទី១ ខ្លះនឹកឃើញត្រង់ទេវទូតទី ២ ឬទី៣ ជាដើម ឯសត្វដែលនឹកមិនឃើញត្រង់ទេវទូតគ្រប់ទាំង ៥ នោះ ព្រះយមរាជតែងជួយនឹករកដោយព្រះអង្គឯង បើនឹកទៅឃើញថាមានធ្វើអំពើកុ

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើនូវកម្មករណ៍ឈ្មោះបញ្ចពិធព័ន្ធន៍ (ចំណងប្រាំប្រការ) ចំពោះបុរសនោះ គឺផ្តេក (បុរសនោះ) ហើយបោះដែកគោលដ៏ក្តៅត្រង់ដៃ (ខាងស្តាំ)១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង១ បោះដែកគោលដ៏ក្តៅ ត្រង់ជើង (ខាងស្តាំ)១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង១ បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង១។ បុរសនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង

---

សលខ្វះ ទ្រង់ក៏បំភ្លឺសត្វនោះឱ្យយល់ឡើង បើទ្រង់នឹករកមើលមិនឃើញទេក៏នៅស្ងៀម នឹកក្នុងព្រះហឫទ័យថា ឱសត្វនេះមុខជានឹងបានទុក្ខធំ។ អដ្ឋកថា។

ខ្លោចផ្សាក្នុងទីនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាលចាប់ផ្តេកបុរសនោះរួចហើយ ទើបចាំងដោយដឹង។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយច្រាសដោយកំបិតព្រា។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុរសនោះនឹងរថ ហើយបរទៅបរមក លើប្រថពីដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ប្រើបុរសនោះឱ្យឡើងភ្នំ ឱ្យ

ចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងក្តៅសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយទំលាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ។ បុរសនោះ ក៏ឆេះនឹងកំសួលពពុះ ក្នុងខ្ទះទង់ដែងនោះ។ កាលបុរសនោះ ឆេះនឹងកំសួលពពុះ ក្នុងខ្ទះទង់ដែងនោះ ចួនកាលអណ្តែតឡើងលើម្តង ចួនកាលលិចចុះក្រោមម្តង ចួនកាលអណ្តែតទៅទទឹងម្តង។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងខ្ទះ

ទង់ដែងនោះ បើបាបកម្មនោះ មិនទានអស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏បោះបុរសនោះទៅក្នុងមហានរក[៧]។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត មានជ្រុង

---

(៧) ប្រែថា នរកធំឈ្មោះអវីចិៗ សព្ទនេះប្រែថា ទីគ្មានចន្លោះ គឺនរកនោះគ្មានចន្លោះ អណ្តាតភ្លើង គ្មានចន្លោះសត្វ គ្មានចន្លោះសេចក្តីទុក្ខ គឺពោរពេញទៅដោយភ្លើង ពេញដោយសត្វនរកៗ រងទុក្ខឥតមានល្ហែ ។ ទំហំអវីចិមហានរកនោះ ខាងបណ្តោយនិងទទឹង ៩០០ យោជន៍ដូចគ្នា កំពស់ជញ្ជាំងមួយៗ ៩ យោជន៍ ឯផ្ទៃផែនដីខាងក្រោមដោលលោហៈ ដំបូលក៏ប្រក់ដោយលោហៈ។ អដ្ឋកថា។

បួន មានទ្វារបួន បែងចែកដោយចំណែកៗ មានរបងដែកព័ទ្ធព័ទ្ធជុំវិញ គ្របដោយគំរបដែក។ ផ្ទៃផែនដីខាងក្រោមនៃមហានរកនេះ សុទ្ធតែដែក មានភ្លើងឆេះច្រាលរន្ទាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗ កាល។

ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង មានអណ្តាតភ្លើងឆេះ ឡើងអំពីជញ្ជាំងខាងកើត ឆាបដល់ជញ្ជាំងខាងលិច។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងលិច ឆាបដល់ជញ្ជាំងខាងកើត។ អណ្តាតភ្លើងឆេះ ឡើងអំពីជញ្ជាំងខាងជើង ឆាបដល់ជញ្ជាំង

ខាងត្បូង។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងត្បូង ឆាប់ដល់ជញ្ជាំងខាងជើង។ អណ្តាតភ្លើង ឆេះឡើងអំពីខាងក្រោម ឆាបដល់ខាងលើ អណ្តាតភ្លើង ឆេះឡើងអំពីខាងលើ ឆាបដល់ខាងក្រោម។ បុរសនោះក៏រងទុក្ខវេទនា ក្លាខ្លាំងខ្លោចផ្សា ក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ។ បុរសនោះ ក៏ស្ទុះដ៏រហ័សទៅត្រង់ទ្វារនោះ។

កាលដែលបុរសនោះស្ទុះទៅ ដោយសន្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលបើជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះដូច្នោះឯង។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ (ក្នុងទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាលបិទទៅវិញ។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលទៅវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងលិចនៃអវីចិមហានរកនោះ ។បេ។ បើកទ្វារខាងជើង ។បេ។ បើកទ្វារខាងត្បូង។ បុរសនោះ ក៏ស្ទុះដោយសន្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ។ កាលបុរសស្ទុះទៅដោយសន្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលបើជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះប្រាកដដូច្នោះឯង។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ (ក្នុង

ទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាល បិទវិញ។ បុរសនោះរងទុក្ខវេទនាក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិន ទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែង ឆ្ងាយទៅម្តង១ សម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ។ បុរស នោះ ក៏ស្ទុះទៅដោយសន្ទុះដ៏រហ័ស ទៅត្រង់ ទ្វារនោះ។ កាលបុរសនោះស្ទុះដោយសន្ទុះដ៏ រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែក ក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះ ឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលបើ

ជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះ ប្រាកដដូច្នោះឯង។ បុរសនោះក៏ស្ទុះទៅតាមទ្វារនោះ។ ម្នាលភិក្ខុទាំងឡាយមានគូថនរក[៨] ដ៏ធំ តាំងនៅបន្ទាប់គ្នានឹងមហានរកនោះឯង។ បុរសនោះធ្លាក់ទៅក្នុងគូថនរកនោះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងគូថនរកនោះសោតមានសត្វទាំងឡាយមាត់ស្រួចដូចម្ជុល កកេរស្បែកក្រៅ លុះកកេរស្បែកក្រៅហើយ កកេរស្បែកក្នុង លុះកកេរស្បែកក្នុងហើយ កកេរសាច់ លុះកកេរសាច់ហើយ កកេរសរ

---

[៨] ប្រែថា នរកពេញហៀរដោយលាមក ។

សៃ លុះកកេរសរសៃហើយ កកេរឆ្អឹង លុះកកេរឆ្អឹងហើយ ទើបខាំស៊ីខួរក្នុងឆ្អឹង។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងគូថនរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ មានកុក្កុលនរក[៩] ដ៏ធំតាំងនៅបន្ទាប់គ្នានឹងគូថនរកនោះឯង។ បុរសនោះ ធ្លាក់ទៅក្នុងកុក្កុលនរកនោះ។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុង

---

[៩] ប្រែថា នរកពេញហៀរដោយផេះក្តៅ ។

កុក្កុលនរកនោះ បើបាបកម្ម មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ មានព្រៃរកាដ៏ធំ ខ្ពស់ត្រដួចឡើងមួយយោជន៍ មានបន្លា ១៦ធ្នាប់ ភ្លើងឆេះក្តៅសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ តាំងនៅបន្ទាប់គ្នានឹងកុក្កុលនរកនោះឯង។ ពួកនិរយបាល ក៏ប្រើបុរសនោះឱ្យឡើងឱ្យចុះអំពីព្រៃរកានោះ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាលើដើមរកានោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ មានព្រៃស្មៅសសិតធំ តាំងនៅបន្ទាប់គ្នានឹងព្រៃរកានោះឯង។ បុរសនោះ ចូលទៅក្នុងព្រៃស្មៅសសិតនោះ។ ខ្យល់បក់ស្លឹកសសិតនោះ មកកាត់ដៃ កាត់ជើង កាត់ទាំងដៃទាំងជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះ (របស់បុរសនោះ)។ បុរសនោះ រងទុក្ខវេទនាក្លាខ្លាំង ខ្លោចផ្សា នៅក្នុងព្រៃសសិតនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ មានស្ទឹងទឹកផ្សាដ៏ធំ តាំងនៅបន្ទាប់គ្នានឹងព្រៃសសិតនោះឯង។

បុរសនោះ ក៏ធ្លាក់ទៅក្នុងស្ទឹងនោះ។ បុរសនោះ ចូនកាលអណ្តែតបណ្តោយខ្សែទឹក ចូនកាលអណ្តែតច្រាសខ្សែទឹក ចូនកាលអណ្តែតទាំងបណ្តោយខ្សែទឹក ទាំងច្រាសខ្សែទឹក ក្នុងស្ទឹងនោះ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងស្ទឹងនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកសន្ទូច ស្ទូចបុរសនោះវាត់ឡើង ដាក់មកលើគោក ហើយសួរយ៉ាងនេះថា នែបុរស អ្នកឯងប្រាថ្នាអ្វី។ បុរសនោះឆ្លើយយ៉ាងនេះថា

បពិត្រលោកដ៏ចំរើន ខ្ញុំឃ្លានបាយ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏យកកង្វេរដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាលសន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយញាត់នូវដុំទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់។ ដុំទង់ដែងនោះក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំទាំងពោះវៀនតូច របស់បុរសនោះចេញមកខាងក្រោម។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាប

កម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស អ្នកឯងប្រាថ្នាអ្វី។ បុរសនោះឆ្លើយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំស្រេកទឹក។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកកង្វេរដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយបង្អក់ទឹកទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺច្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់។ ទឹកទង់ដែងនោះ ក៏ឆេះបបូរមាត់

ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំទាំងពោះវៀនតូច របស់បុរសនោះចេញមកខាងក្រោម។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាបកម្មនោះមិនអស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះទំលាក់បុរសនោះ ទៅក្នុងមហានរកវិញ។

ម្នាលភិក្ខុទាំងឡាយ រឿងរ៉ាវ ធ្លាប់មានមកហើយថា ព្រះយមរាជ មានសេចក្តីត្រិះរិះដូច្នេះថា បានឮថា សត្វទាំងឡាយណា ធ្វើបាបកម្ម ក្នុងលោក សត្វនោះឯង រមែងត្រូវ

គេធ្វើកម្មករណ៍ផ្សេងៗ មានសភាពយ៉ាងនេះ ឱហ្ន៎ អាត្មាអញ សូមឱ្យបានអត្តភាពជាមនុស្ស ឱ្យទាន់ព្រះតថាគតអរហត្តសម្មា-សម្ពុទ្ធ ត្រាស់ឡើងក្នុងលោក សូមឱ្យអាត្មាអញ ចូលទៅអង្គុយជិតព្រះមានព្រះភាគអង្គនោះ បើព្រះមានព្រះភាគអង្គនោះ ទ្រង់សំដែងធម៌ប្រោសអាត្មាអញ សូមឱ្យអាត្មាអញយល់ច្បាស់ នូវធម៌របស់ព្រះមានព្រះភាគអង្គនោះ។ ម្នាលភិក្ខុទាំងឡាយ ឯតថាគត មិនមែនបានស្តាប់រឿងនោះឯង អំពីសមណ ឬព្រាហ្មណ៍ដទៃណាមួយ ហើយ (នាំមក) សំដែងទេ តាមដែលពិតនោះតថាគត សំដែង

រឿងដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង យល់ខ្លួនឯង តែមួយយ៉ាង។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ លុះព្រះសុគត ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ទើបព្រះសាស្តា ទ្រង់ត្រាស់និពន្ធគាថានេះតទៅថា

មាណពទាំងឡាយណា ដែលយមរាជដាស់តឿន ដោយទេវទូតទាំងឡាយហើយ ក៏នៅតែប្រមាទ មាណពទាំងនោះឯង ជាអ្នកបាននូវកាយ ក៏ថោកទាប រមែងសោកសៅ អស់កាលយូរអង្វែង ចំណែកមាណពណា ក្នុងលោកនេះ ជាសប្បុរស

មាន សន្តានស្ងប់រម្ងាប់ ដែលយមរាជ ដាស់តឿន ដោយទេវទូតទាំងឡាយ ហើយ តែងមិនប្រមាទក្នុងអរិយធម៌ ក្នុងកាលណាឡើយ រមែងឃើញនូវភ័យក្នុងឧបាទានជាហេតុកើតឡើងនៃជាតិ និងមរណៈ តែងចុះចិត្តស៊ប់ ក្នុងព្រះនិព្វានជាធម្មជាតិ និងមរណៈ ព្រោះមិនប្រកាន់មាំ មាណពនោះឯង ជាអ្នកដល់នូវទីដ៏ក្សេម មានសេចក្តីសុខ រលត់កិលេសក្នុងបច្ចុប្បន្ន ជាអ្នកកន្លងផុតនូវពៀរ និងភ័យទាំងពួង បានឆ្លងផុតនូវទុក្ខទាំងពួង។

**ចប់ទេវទូតសូត្រ**

# នាមសប្បុរសជួយឧបត្ថម្ភថវិកា
# បោះពុម្ពសៀវភៅ

| | |
|---|---|
| ១_ឧបាសិកា សុម៉ាលី វណ្ណា | U.S.A ៤០០ ដុល្លា |
| ២_ឧបាសិកា ប៉ាច់ ប៊ុន | |
| ៣_ឧបាសិកា គង់ លន់ | |
| ៤_លោក ប៊ុត ទិត្យសុធា ភ្នំពេញ | ៣០០ ដុល្លា |
| ៥_ភិក្ខុ សួន ពៅ | ១០ ដុល្លា |
| ៦_ព្រះធម្មាចារ្យ ឯក សារិន | ៥ ០០០ រៀល |
| ៧_ភិក្ខុ អ៊ិត វណ្ណមុនី | ១០០ ក្បាល |
| ៨_ភិក្ខុ ឃឹម ជេន | ២០ ០០០ រៀល |
| ៩_ភិក្ខុ មូល ពៅ | ៣០ ០០០ រៀល |
| ១០_សាមណេរ រ៉ន រត្ន | ១០ ០០០ រៀល |

១១_សាមណេរ វ៉ា ម៉ារ៉ាឌី ១០ ០០០ រៀល

១២_សាមណេរ វីន ១០ ០០០ រៀល

១៣_សាមណេរ អ៊ួង វណ្ណៈ ២០ ០០០ រៀល

១៤_សីលវតី គឹម សូហៀង ៥០ ០០០ រៀល

១៥_សីលវតី គឹម វីម ១០ ០០០ រៀល

១៦_សីលវតី គាំ អ៊ីម ៥ ០០០ រៀល

១៧_សីលវតី ហ៊ុម ស្រីមុំ ៥ ០០០ រៀល

១៨_សីលវតី សំ សូត្រ ៥ ០០០ រៀល

១៩_សីលវតី ទៀប ដានី ៥ ០០០ រៀល

២០_សីលវតី ប៉ូវ រួចសៀន ព្រមទាំង

កូន និងចៅ ២០ ០០០ រៀល

២១_សីលវតី ម៉ែន ផៃ ១០ ០០០ រៀល

២២_សីលវតី បូ គឹមសេង ២០ ០០០ រៀល

២៣_សីលវតី កោះ ប៊ុនថាច ៤០ ០០០ រៀល

២៤_សីលវតី អ៊ុក ស្រីយ៉ាន ១០ ដុល្លា

២៥_សីលវតី ឡូញ វីន ៥ ដុល្លា

២៦_សីលវតី ជ័យ ចាន់ឌី ១០ ០០០ រៀល

២៧_សីលវតី លី ហុងស៊ាន ១០ ០០០ រៀល

២៨_សីលវតី ស៊ុន ស៊ុម ៥ ០០០ រៀល

២៩_សីលវតី ខៀវ ឥន្ទ ១០ ដុល្លា

៣០_សីលវតី ណៃ សាម៉ុន ៥ ០០០ រៀល

៣១_សីលវតី លឹម ខេងង៉ោ ព្រមទាំងបុត្រ
និងចៅ ៥ ដុល្លា

៣២_សីលវតី តូ ហ៊ាង ១០ ០០០ រៀល

៣៣_សីលវតី ជា អ៊ិន ៥ 000 រៀល

៣៤_សីលវតី យឿន យ៉ែម ១0 000 រៀល

៣៥_សីលវតី ប៉ែន អ៊ាងសែ ១0 000 រៀល

៣៦_សីលវតី ប៉ែន អ៊ាងហៃ ១0 000 រៀល

៣៧_សីលវតី ប្រាក់ ច័ន្ទស៊ីផារ៉ែន ១0 000 រៀល

៣៨_សីលវតី កើត គឹមអាន ២0 000 រៀល

៣៩_សីលវតី តាំង ហៃ ២0 000 រៀល

៤0_សីលវតី គឹម ណារី ២0 000 រៀល

៤១_ឧបាសិកា តុង ប៉េងហុង ៥0 000 រៀល

៤២_ឧបាសិកា គង់ ភុក ២0 000 រៀល

៤៣_ឧបាសិកា ទូច ណារ៉ុង ១0 ដុល្លា

៤៤_ឧបាសិកា ទូច ប្រាង ១0 000 រៀល

៤៥_ឧបាសិកា គ្រីន អេង ១ ០០០ រៀល

៤៦_ឧបាសិកា ធី សុខ ៥ ០០០ រៀល

៤៧_ឧបាសិកា សួ យូឡាង ៥ ០០០ រៀល

៤៨_ឧបាសិកា ជីន ព្រមទាំងបុត្រ និង

ចៅ ៥ ដុល្លា

៤៩_ឧបាសិកា នាង កឹម ព្រមទាំងបុត្រ និង

ចៅ ៣ ដុល្លា

៥០_ឧបាសិកា អៀម ឳ ១០ ០០០ រៀល

៥១_ឧបាសិកា វណ្ណនី (ពៅ) ព្រមទាំងស្វាមី និង

បុត្រ ៥០ ០០០ ដុង

៥២_ឧបាសិកា ឡាំ គីមណៃ ១០ ០០០ រៀល

៥៣_ឧបាសិកា សៀង លី ៥ ០០០ រៀល

៥៤_ឧបាសិកា ភិន អ៊ា ៥០ ០០០ ដុង

៥៥_ឧបាសិកា ឃន និងតា ឌុល ព្រមទាំង
បុត្រ ១០ ដុល្លា

៥៦_ឧបាសិកា ប៊ុន សុភាព (ញ៉) ១០ ០០០ រៀល

៥៧_ឧបាសិកា ណាំ ព្រមទាំងបុត្រ និង
ចៅ ១០ ដុល្លា

៥៨_ឧបាសិកា ឃូ សេង ៥០ ០០០ រៀល

៥៩_ឧបាសិកា ឆេង ឡាំង ៥០ ០០០ ដុង

៦០_ឧបាសិកា ហ៊ុន សុខ ៥ ០០០ រៀល

៦១_ឧបាសិកា វ៉ែន សុខា ៥ ០០០ រៀល

៦២_ឧបាសិកា ឈីវ ផេង ១០ ០០០ រៀល

៦៣_ឧបាសិកា តួច ជា ៥ ០០០ រៀល

៦៤_ឧបាសិកា ហៀប គីមលាង ១០ ០០០ រៀល

៦៥_ឧបាសិកា កើត គុយលាង ២០ ០០០ រៀល

៦៦_ឧបាសិកា ស្រ៊ិន ៤ ០០០ រៀល

៦៧_ឧបាសិកា ភុធ ៣ ០០០ រៀល

៦៨_ឧបាសិកា ញ៉ើក ២០ ០០០ ដុង

៦៩_ឧបាសក ហង្ស សារឿន ៥០ ០០០ ដុង

៧០_ឧបាសិកា ហ៊ាង ១០ ០០០ រៀល

៧១_ឧបាសិកា ឈន សែ ២ ៥០០ រៀល

៧២_ឧបាសិកា ហឿង+បុត្រ+ចៅ ៤០ ០០០ ដុង

៧៣_យាយ ច្រិក ២០ ០០០ ដុង

៧៤_យាយ វណ្ណ ២០ ០០០ ដុង

៧៥_ឧបាសក ហ៊ុយ និងបុត្រ ១០ ០០០ រៀល

៧៦_ឧបាសក ខ្នា និងភរិយា+បុត្រ ១០ ដុល្លា

៧៧_ឧបាសក ធឿង + ឧបាសិកា ខុម និង

បុត្រ និងចៅ ៥០ ០០០ ដុង

៧៨_តា ហ៊ាង យាយ សេង ១០០ ០០០ ដុង

៧៩_តា ប៉ុង យាយ ខែត +បុត្រ ២០ ០០០ រៀល

៨០_តា យុី យាយ យុត ៤០ ០០០ ដុង

៨១_តារឿង យាយសុនិ(សណ្ដារ) ២០០០០ រៀល

៨២_តា យ៉ាន យាយរឿន ១០ ០០០ រៀល

៨៣_លោកហុង និងភរិយា+បុត្រ១០ ០០០ រៀល

៨៤_លោកភាព និងនាងធីតា ៥០ ០០០ ដុង

៨៥_លោក ហួយ ភរិយា+បុត្រ ២០ ០០០ រៀល

៨៦_លោកសុខគង្គា+ភរិយា+បុត្រ ១០០០០រៀល

៨៧_អ្នកស្រីសុខគន្ធា+ស្វាមី+បុត្រ១០០០០ រៀល

៨៨_ សីលវន្ត លួន ភី ៥ ០០០ រៀល

៨៩_ទាយក អៀង ផាន់ណូ ១០ ០០០ រៀល

៩០_យុវជន សីហា ១១ ១០០ រៀល

៩១_សីលវតី បុយ សុខ ៥ ដុល្លា

៩២_ឧបាសិកា សួយ សុខា ៥០ ដុល្លា

៩៣_សីលវន្តអាចារ្យ ឈួន ប៉ូ ២០ ០០០ រៀល

៩៤_សីលវន្ត ជា ខេង ៥ ០០០ រៀល

៩៥_សីលវន្ត ព្រំ យន ១០ ០០០ រៀល

៩៦_សីលវន្ត ជេត យាន់ ៥ ០០០ រៀល

៩៧_សីលវន្ត ហ៊ុន ម៉ាច ៥ ០០០ រៀល

៩៨_សីលវន្ត សោម សន ៥ ០០០ រៀល

៩៩_ឧបាសិកា ឡេង ចេងលាង ៥០ ០០០ រៀល

# នាមសប្បុរសជួយឧបត្ថម្ភថវិកា

# បោះពុម្ពសៀវភៅ

# លើកទី ២

១_មណ្ឌលវិបស្សនាធុរៈក្អមសំណ ៥២ ០០០ ៛

២_សីលវន្ត ផៃ ផាន់ ១០ ០០០ រៀល

៣_សីលវតី ធឹម ស៊ីណា ៥ ០០០ រៀល

៤_សីលវតី ជា សេង ៥ ០០០ រៀល

៥_សីលវតី រឿង ឌុម ៥ ០០០ រៀល

៦_សីលវតី ហ៊ុន ឡាន ៥ ០០០ រៀល

៧_សីលវតី វណ្ណ សារ៉េត ៥ ០០០ រៀល

៨_សីលវតី ស៊ុយ សុផាត ៥ ០០០ រៀល

៩_សីលវតី សុខ ណន ៥ ០០០ រៀល

១០_ឧបាសិកា ជ័យ ស៊ីនួន ៥ ០០០ រៀល

១១_ឧបាសិកា ហ៊ុន ធីរ៉ា ១០ ០០០ រៀល

១២_លោកគ្រូពេទ្យ ជា សម្បត្តិ ៥០ ដុល្លា

១៣_លោក មុំ ម៉ារ៉ា និង អ្នកស្រី ប៊ុត ច័ន្ទធី

សហរដ្ឋអាមេរិក ៦០ ដុល្លា

១៤_កញ្ញា ប៊ុត ច័ន្ទរ៉ាវី ៥ ដុល្លា

១៥_កញ្ញា សាយ ពិដោ ៥ ដុល្លា

១៦_លោក អ៊ុក ផាន់ណា និង ភរិយា បុត្រ $ ៥

១៧_លោក អ៊ុក សុវណ្ណ និង ភរិយា

បុត្រ ២០ ០០០ រៀល

១៨_លោក ជាទិត្យា រ៉ានី ១០ ០០០ រៀល

១៩_កញ្ញា អ៊ុក សុភាពិសី ១០ ០០០ រៀល

២០_លោក ម៉ាន់ សារាយ ១០ ០០០ រៀល

២១_លោក ប៊ុត សរតារាវណ្ណ និង

កែវ រត្នមុនី ១៥ ដុល្លា

២២_លោក គ្រៀល ស៊ីណា និង ភរិយា

បុត្រ ១០ ០០០ រៀល

២៣_អ្នកស្រី អ៊ុក វួច និង ស្វាមី ១០ ០០០ រៀល

២៤_លោក គ្រៀល វណ្ណារិន និង ភរិយា

បុត្រ ២០ ០០០ រៀល

២៥_លោក ពុំ សុខសក្កដា ៥ ០០០ រៀល

២៦_លោក ខេង គីមហេង ៥ ០០០ រៀល

២៧_លោក ពុំ សុខឧត្តម ៥ ០០០ រៀល

២៨_លោក គ្រៀល វណ្ណនី ១០ ០០០ រៀល

២៩_លោក ប៊ុត សុក្រសុភក្ត្រ័ ១០ ដុល្លា

៣០_កញ្ញា ខេង សុខលី ១០ ០០០ រៀល

៣១_លោក សិទ្ធី រិទ្ធ និងភរិយា បុត្រ១០ ០០០ ៛

៣២_លោក សួន សំរ៉េណូ និង ភរិយា

បុត្រ ១ ដុល្លា

៣៣_លោក ងួន សីហា ១ ដុល្លា

៣៤_អ្នកស្រី ម៉ុលម៉ាច និង បុត្រ ៥ ០០០ រៀល

៣៥_កញ្ញា ជា រដ្ឋា ៥ ០០០ រៀល

៣៦_លោក ឆាង សុធា ៥ ០០០ រៀល

៣៧_លោក ម៉ក់ វណ្ណីដេ និង ភរិយា

បុត្រ ១០ ០០០ រៀល

៣៨_អ្នកស្រី ធឿន សារីម បុត្រ ៥ ០០០ រៀល

៣៩_អ្នកស្រី ម៉ាន់ សត្យា បុត្រ ១០ ០០០ រៀល

៤០_លោក គ្រៀល វណ្ណារ៉ា និង

អ្នកស្រី អ៊ុក ផល្លា ២០ ដុល្លា

៤១_ឧបាសក ជ័យ និងឧបាសិកា សារិ

បុត្រ ៤២ ០០០ រៀល

៤២_ឧបាសក ឃី សោម និងឧបាសិកា

សុខ ឃីម ១០ ០០០ រៀល

៤៣_ឧបាសក ស្រេង ហុង និងឧបាសិកា

អ៊ីង ខន ១០ ០០០ រៀល

៤៤_ឧបាសក ផូ ជីវ និងឧបាសិកា

ឆន ឡេង ១០ ០០០ រៀល

៤៥_ឧបាសិកា ស្រ៊ី ស្រេង និងបុត្រ ១០ ០០០ ៛

៤៦_ឧបាសក មិត្ត និងឧបាសិកា លន ១០ ០០០ ៛

៤៧_ឧបាសិកា ញ៉ៀ និង កូនចៅ ១០ ០០០ រៀល

៤៨_ឧបាសិកា ជួន អ៊ី ១០ ០០០ រៀល

៤៩_ឧបាសិកា ម៉ុច ១០ ០០០ រៀល

៥០_យុវជន ខន ធី ៥ ០០០ រៀល

៥១_អ្នកស្រី ភីដានី និងបុត្រ ៥ ០០០ រៀល

៥២_ឧបាសក ម៉ែន ឈន និងបុត្រ ១០ ០០០ ៛

៥៣_ឧបាសក យូ តុំ ១០ ០០០ រៀល

៥៤_ឧបាសក ហោ សុផា (តាក់ស៊ី) ១០ ០០០ ៛

៥៥_សីលវតី ប្រាក់ ច័ន្ទតារា ២០ ០០០ រៀល

៥៦_ឧ_ស លី យ៉ី និង ឧ_សិ ចាន់ យុត១០ ដុល្លា

៥៧_លោក សេរី សុផល ១០ ០០០ រៀល

៥៨_លោក លន និង ឱ_សិ លត១០ ០០០ រៀល

៥៩_កុមារី សេរី ទានិកា ៥ ០០០ រៀល

៦០_កញ្ញា ទុំ និមល ៥ ០០០ រៀល

៦១_ទុំ វិសាល និងភរិយា ៥ ០០០ រៀល

៦២_កញ្ញា ទុំ ទេព្ណម្ភ ៥ ០០០ រៀល

៦៣_លោក សុបិន និងភរិយា បុត្រ ១០ ០០០ ៛

៦៤_សីលវន្ត ហ៊ល គង់ ១០ ០០០ រៀល

៦៥_កុមារី ហ៊ល ម៉ាឡា ៥ ០០០ រៀល

៦៦_កុមារី ហ៊ល ម៉ាឡៃ ៥ ០០០ រៀល

៦៧_សីលវតី មាស មួយ ២៥ ដុល្លា

៦៨_សីលវតី ម៉ែ ផៃ ១០ ០០០ រៀល

៦៩_ឧ.ស គុង កន និងឧ.សិ ប៊ូ ផេន ៥០ ០០០៛

៧០_ឧ.សិ គុង ប៉េងហុង និងបុត្រ ២០ ០០០៛

៧១_ឧ.ស សៀក យូប៉េង និងឧ.សិ គុង ប៉េង

ហេង ព្រមទាំងបុត្រ ១០០ ០០០ រៀល

៧២_លោក សុខ ផល និងភរិយា

ព្រមទាំង បុត្រ ២០ ០០០ រៀល

៧៣_សីលវតី យ៉េ ផលគុណ ៥ ០០០ រៀល

៧៤_សីលវតី ឆេត ស៊ាងនី ៥ ០០០ រៀល

៧៥_សីលវតី កែវ មុលី ១០ ០០០ រៀល

៧៦_មាន មន (ពៅ) ៥ ០០០ រៀល

៧៧_សីលវតី កឹម គីមយ៉ាង ៥ ០០០ រៀល

៧៨_យុវជន ឱល វុទ្ធី ៥ ០០០ រៀល

៧៩_យុវជន ឌល ភក្តី ៥ ០០០ រៀល

៨០_យុវជន ឌល សុច័ន្ទត្រា ៥ ០០០ រៀល

៨១_យុវជន ហ៊ង រិទ្ធី ស័ក្ក ៥ ០០០ រៀល

៨២_យុវជន ហ៊ង សុភា ៥ ០០០ រៀល

៨៣_យុវជន ហ៊ង សុភ័ណ ៥ ០០០ រៀល

៨៤_កញ្ញា ឌល វណ្ណរី ៥ ០០០ រៀល

៨៥_កញ្ញា ឌល មេត្តា ៥ ០០០ រៀល

៨៦_កញ្ញា ឌល លីដា ៥ ០០០ រៀល

៨៧_លោក សៅ ពូន និងនាងហ៊ង សាអែម

ព្រមទាំងបុត្រ ៥ ០០០ រៀល

៨៨_ឧ.សិ ភិន អ៊ា និងបុត្រ និងចៅ ១០ ០០០ ៛

៨៩_ឧ.ស សែម ធឿង និងឧ.សិ សុខុម

ព្រមទាំងបុត្រ ១០ ០០០ រៀល

៩០_ទុំ វច្ចនី ៥ ០០០ រៀល

៩១_ទុំ ទិវា ៥ ០០០ រៀល

៩២_សីលវតី អ៊ុំង គឹមលន ១ ដុល្លា

៩៣_ព្រះភិក្ខុ យ៉ាន់ យ៉េត ៤០ ដុល្លា

៩៤_លោក ឃឹមគឹម ឈាន និងភរិយា ព្រមទាំង

បុត្រ ១០ ០០០ រៀល

៩៥_កញ្ញា ឃឹមគឹម ស្រីមុំ ៥ ០០០ រៀល

៩៦_កញ្ញា ឃឹមគឹម ស្រីម៉ាច ៥ ០០០ រៀល

៩៧_កញ្ញា ឃឹមគឹម សុជាតា ៥ ០០០ រៀល

៩៨_កុមារា ឃឹមគឹម ពន្លក ៥ ០០០ រៀល